# សីមាពន្ធនវិនិច្ឆ័យ

រៀបរៀងដោយ

**ង៉ាន់ ចាន់សារ៉េន**

ត្រួតពិនិត្យដោយ

**ក្រុមជំនុំពុទ្ធិកបណ្ឌិតសភា**

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥១

គ.ស.២០០៧

| | |
|---|---|
| ឈ្មោះសៀវភៅ | សីមាពន្ធនវិនិច្ឆ័យ |
| រៀបរៀងដោយ | ភ៉ន់ ចាន់សារ៉ែន |
| ត្រួតពិនិត្យដោយ | ក្រុមជំនុំពុទ្ធិកបណ្ឌិតសភា |
| ទីតាំងធ្វើ | ការិយាល័យបច្ចេកទេស ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយរបស់ | ពុទ្ធិកបណ្ឌិតសភានៃសាកល-វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| កាលបរិច្ឆេទ | ថ្ងៃទី ១៦-១៧-១៨ ខែ ពិសាខ ឆ្នាំ ជូត សំរឹទ្ធិស័ក ព.ស.២៥៥១ គ.ស.២០០៨ |
| រក្សាសិទ្ធិដោយ | ពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ |
| បោះពុម្ពលើកទី ៣ | តាមឯកសារដើម |

Printed for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

Mobile Web: m.budaedu.org



**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

## ការបោះពុម្ពផ្សាយ

ពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា បានចាត់ចែងបោះពុម្ពនូវសៀវភៅធម៌ជាច្រើនកន្លងមកហើយ ។

នេះជាសៀវភៅមួយទៀត ដែលមានឈ្មោះថា "**សីមាពន្ធន-វិនិច្ឆ័យ**" ដែលបានរៀបរៀងនិងចងក្រងដោយលោក **ម៉ាន់ ចាន់សារ៉េន** ដែលជាអគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា ។

ពុទ្ធិកបណ្ឌិតសភាបោះពុម្ពសៀវភៅនេះឡើងដោយមានគោលបំណង ៖

-ជំនួយដល់ការសិក្សារបៀបធ្វើសីមាកម្ម

-ជាប្រទីបដល់សាធុជនដែលជាអ្នកគោរពព្រះពុទ្ធសាសនា

-ផ្សព្វផ្សាយនូវអនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធ ។

**ពុទ្ធិកបណ្ឌិតសភា** សូមបោះពុម្ពសៀវភៅធម៌នេះ ទុកជាសម្បត្តិរបស់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាតរៀងទៅ ។

ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# **សម្ភោធនីយកថា**

ខ្ញុំសូមសរសើរនូវវិរិយភាពរបស់លោក **ទ៉ាន់ ចាន់សារ៉េន** ដែលបានព្យាយាមរៀបរៀងនិងចងក្រងនូវសៀវភៅនេះឡើង ។

លោក **ទ៉ាន់ ចាន់សារ៉េន** បានរៀបរៀង និងចងក្រងនូវសៀវភៅធម៌ជាច្រើនកន្លងមកហើយ ។ សៀវភៅធម៌នីមួយៗនេះមានសារៈប្រយោជន៍ដល់សិក្ខាកាម ទាំងបព្វជិត ទាំងឧបាសកឧបាសិកា និង កុលបុត្រ-កុលធីតាទាំងឡាយ ជាអ្នកប្រាថ្នានូវការសិក្សានូវព្រះពុទ្ធវចនៈរបស់ព្រះជិនស្រី ។

នេះជាសៀវភៅស្នាដៃមួយទៀត ដែលមានឈ្មោះថា **សីមា-ពន្ធនវិនិច្ឆ័យ** បានរៀបរាប់ពីសីមាកថា ដែលជាប់ទាក់ទងនឹងសង្ឃកម្មរបស់ព្រះភិក្ខុសង្ឃ មានរបៀបពន្យល់ដកស្រង់ពីគម្ពីរធម៌ដ៏សំខាន់ក្នុងព្រះពុទ្ធសាសនាមានព្រះត្រៃបិដក អដ្ឋកថា ដីកា យោជនា ផ្នែកខាងព្រះវិន័យ គួរដល់ការសិក្សាយ៉ាងល្អ និងឈ្លាសប្រតិពលក្នុងការចងសីមា មានចងខណ្ឌសីមាជាដើម យ៉ាងងាយសម្រាប់ព្រះវិនយធរទាំងឡាយ ។

អាស្រ័យហេតុនេះ ខ្ញុំសូមកោតសរសើរចំពោះស្នាដៃ និងការតាំងចិត្តយ៉ាងមុះមុតក្នុងការរៀបរៀង និងចងក្រងសៀវភៅនេះឲ្យបានសម្រេចជាស្ថាពរ ហើយបោះពុម្ពផ្សាយ ជាសម្បត្តិរបស់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាតរៀងទៅ ។

សូមស្នាដៃដ៏ពិសិដ្ឋនេះ សម្រេចជាឥដ្ឋមនុញ្ញផលដល់បព្វជិតគ្រប់ព្រះអង្គ និងគ្រហស្ថគ្រប់រូប ហើយសម្រេចនូវពុទ្ធិចិត្ត ដូចសេចក្តីប្រាថ្នា ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា ខ្ញុំបាទសូមអនុមោទនានូវកុសលចេតនារបស់ពុទ្ធសាសនិកជនដែលបានចូលរួមបោះពុម្ពសៀវភៅធម៌នេះ ផ្សព្វផ្សាយជាធម្មទាន ។

សូមសត្វលោកទាំងឡាយ បានប្រកបដោយសេចក្តីសុខគ្រប់ប្រការជានិច្ចនិរន្តរ៍ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**បណ្ឌិត ក្រុល ផេង**

ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# អារម្ភកថា

សីមាកថា សំខាន់ជាងគេបង្អស់នៅក្នុងព្រះវិន័យដែលជាពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ។ សង្ឃកម្មទាំងពួងក្នុងព្រះពុទ្ធសាសនាត្រូវតែអាស្រ័យនូវសីមា-កថានេះចាំបាច់ជាទីបំផុត ដូចជាការធ្វើឧបសម្បទ ឲ្យមានព្រះភិក្ខុសង្ឃជាភិក្ខុភាវៈត្រូវតែមានក្នុងសីមានេះយ៉ាងពិតប្រាកដ ។

អាស្រ័យសីមាសំខាន់បំផុតយ៉ាងនេះ ទើបខ្ញុំព្រះករុណាខ្ញុំបាទសិក្សាស្រាវជ្រាវ ត្រួតពិនិត្យក្នុងព្រះត្រៃបិដក អដ្ឋកថាដីកា យោជនា និងសៀវភៅសីមាវិនិច្ឆ័យផ្សេងៗមករៀបរៀងជារូបរាងសៀវភៅនេះឡើង ។ ដោយអាស្រ័យខ្ញុំព្រះករុណា ខ្ញុំបាទធ្លាប់បង្រៀននូវសីមាកថានេះជាច្រើនដង ដល់សព្រហ្មចារីទាំងឡាយផង (កាលខ្ញុំនៅជាបព្វជិត) និងធ្លាប់ប្រជុំសិក្សាស្រាវជ្រាវជាមួយធម្មាចារ្យ និងលោកអ្នកឈ្លាសក្នុងសីមាកថានេះច្រើនដងរឿយៗមកផង ក៏ធ្វើឲ្យខ្ញុំព្រះករុណា ខ្ញុំបាទអាចមានសមត្ថភាពបន្តិចបន្តួចក្នុងការសរសេរសៀវភៅនេះឡើង ។ កាលពីមុនខ្ញុំមិនធ្លាប់គិតថា ធ្វើជាសៀវភៅបោះពុម្ពផ្សាយនោះទេ ។ តែពេលខ្ញុំអានសៀវភៅសីមាវិនិច្ឆ័យជាច្រើនក្បាលដែល

បានរៀបរៀងឡើងមករួចហើយ ស្រាប់តែជំរុញទឹកចិត្តខ្ញុំឲ្យធ្វើសៀវភៅ "សីមាពន្ធនវិនិច្ឆ័យ"នេះឡើងមួយក្បាលទៀត ដើម្បីជាប្រយោជន៍ដល់វិនយធរទាំងឡាយផង សម្រេចបាននូវបុណ្យដ៏ធំធេងដល់ខ្ញុំព្រះករុណាផង ។

ការរៀបរៀងសៀវភៅនេះ ខ្ញុំមិនបានសរសេរដោយអត្តនោមតិឡើយ ។ ការពន្យល់ឬអធិប្បាយខ្ញុំបានដកចេញពីគម្ពីរធំៗ ដូចជាព្រះវិនយបិដក មហាវគ្គ លេខ ៦ ត្រង់ឧបោ-សថក្ខន្ធកៈ អដ្ឋកថា ដីកា យោជនា ជាដរាប ។ ការចង្អុលបង្ហាញគម្ពីរត្រង់ពាក្យដកមកនេះ ដើម្បីងាយស្រួល ដល់អ្នកសិក្សាទាំងឡាយធ្ងន់ចិត្ត នូវសាធកៈដែលមានមកនោះៗ ។ ម្យ៉ាងទៀតសមដូចពាក្យបុរាណាចារ្យពោលថា "វាក្យំ សាធកា-វិកលំ យំ តំ ហោតិ ពហ្វាគរុ" ពាក្យនិយាយដែលមិនមានគោលស្ថានអាងអាស្រ័យ (សាធកៈ) ជាពាក្យនិយាយស្រោលមែនទែន ។

តែទោះបីជាយ៉ាងណាក៏ដោយ កិច្ចការងារទាំងឡាយតែងតែមានការភ្លាំងភ្លាត់ខ្វះមិនខាន ។ កាលបើយ៉ាងនោះ សូម

វិញ្ញូជនទាំងឡាយ ដែលជាអ្នកឈ្លាសក្នុងសីមាកម្មមេត្តាជួយកែលម្អដោយកុសលចិត្តផងចុះ ។ម្យ៉ាងទៀត ខ្ញុំព្រះករុណា ខ្ញុំបាទជាអ្នករៀបរៀង សូមអធ្យាស្រ័យអភ័យទោសទុកជាមុននូវកង្វះខាតទាំងនោះ ដែលបានកើតឡើងដោយប្រការណាមួយដោយអចេតនា ។

សូមកុសលកម្ម ដែលបានសម្រេចហើយដោយបុញ្ញកម្មនេះ ប្រគេន-ជូន ចំពោះព្រះសង្ឃគ្រប់ព្រះអង្គ គ្រូឧបជ្ឈាចារ្យ មាតាបិតា ញាតកាទាំងអតីតជាតិនិងបច្ចុប្បន្នជាតិ និងអ្នកដែលបានស្គាល់ខ្ញុំទាំងអស់ សូមអនុមោទនាទទួលយកចុះ ។

សូមព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា
រុងរឿងចម្រើនជានិរន្តរ៍។

ភ្នំពេញថ្ងៃ ព្រហស្បតិ៍ ៦ កើត ខែ ផល្គុន ព.ស.២៥៥០

ត្រូវនឹងថ្ងៃទី ២២ ខែ កុម្ភៈ គ.ស.២០០៧

**ទ៊ាន់ ចាន់សារ៉ែន**

# អនុមោទនកថា

សៀវភៅ "**សីមាពន្ធនវិនិច្ឆ័យនេះ** " ត្រូវបានបោះពុម្ពលើកទី១ចែកជាធម្មទានក្នុងវត្តអម្ពវ័ន ហៅវត្ត ព្រៃស្វាយ ស្ថិតនៅក្នុងភូមិថ្មុកឈើទាល ឃុំ សុព័រទេព ស្រុក ច្បារមន ខេត្តកំពង់ស្ពឺ ។ បោះពុម្ពលើកទី ២ ក្នុងពិធីបញ្ចុះខណ្ឌសីមា វត្តភណ្ឌាគារិការាម (ហៅវត្តឃ្លាំង) ស្ថិតនៅភូមិ ឃ្លាំង ឃុំ ឈើកាច់ ស្រុក បាភ្នំ ខេត្ត ព្រៃវែង ។ កម្មវិធីបុណ្យនេះប្រារព្ធធ្វើនៅថ្ងៃ ១២-១៣-១៤ កើត ខែ ពិសាខ ឆ្នាំ ជូត សំរិទ្ធិស័ក ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី ១៦-១៧-១៨-ខែ ឧសភា ឆ្នាំ ២០០៨ ។

សូមអនុមោទនាចំពោះពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លាបរិច្ចាគប្រាក់ចាត់ចែងបោះពុម្ពសៀវភៅនេះ ។ ដោយអំណាចធម្មទាននេះ សូមពុទ្ធបរិស័ទទាំងនោះ បានកុសលុបនិស្ស័យសម្រេចនូវបញ្ញាសម្មាទិដ្ឋិ និងចាក់ធ្លុះនូវអរិយសច្ចធម៌ កុំបីក្លាយជាប្រការដទៃឡើយ ។

**វ៉ាន់ ចាន់សារ៉ែន**

# មាតិកាអត្ថបទ


| មាតិកា | ទំព័រ |
| --- | --- |
| ១.សីមាមាន ២ ប្រភេទ | ១ |
| ២.អពទ្ធសីមាមាន ៣ ប្រភេទ | ៣ |
| ៣.គាមសីមា | ៥ |
| ៤.វិសុំគាមសីមា | ១២ |
| ៥.សត្តព្ភន្តរសីមា | ៣០ |
| ៦.ឧទកុក្ខេបសីមា | ៣៦ |
| ៧.ជាតស្រះ | ៤៧ |
| ៨.ពទ្ធសីមា | ៥០ |
| ៩.សីមាវិបត្តិ ១១ យ៉ាង | ៥០ |
| ១០.សម្បត្តិ ៣ យ៉ាង | ៥២ |
| ១១.និមិត្តសម្បត្តិ | ៥៣ |
| ១២.អធិប្បាយបាសាណនិមិត្ត | ៥៤ |
| ១៣.បរិសសម្បត្តិ | ៥៥ |
| ១៤.កម្មវាចាសម្បត្តិ | ៥៦ |
| ១៥.សីមាពន្ធនវិធី | ៥៧ |

១៦.មហាសីមា ៥៧

១៧.សីមាពីរជាន់ ៥៨

១៨.ប្ញស៍សីមាពីរជាន់ ៦១

១៩.ខណ្ឌសីមា ៦៣

២០.ការកំណត់និមិត្ត ៦៤

២១.ពិធីដកសីមា ៦៨

២២.របៀបធ្វើតាកផបញ្ចាន់សីមា ៧១

២៣.របៀបធ្វើតាកផប៉ុនគ្រែ ៧៥

២៤.ញត្តិសន្មតសមានសំវាសកសីមា ៧៨

២៥.ញត្តិសន្មតតិចីវរាវិប្បវាសសីមា ៨០

២៦.ដកតិចីវរាវិប្បវាសសីមា ៨២

២៧.ដកសមានសំវាសកសីមា ៨៤

២៨.សេចក្ដីបញ្ជាក់បាឋៈដកនិងសន្មតសីមា ៨៦

២៩.ហត្ថបាសនៃសង្ឃកម្ម ៩០

៣០.សីមាសង្ករៈ ៩៣

## បណាមគាថា

សុគតំ សុគតំ សេដ្ឋំ     កុសលំ–កុសលំ ជហំ
អមតំ អមតំ សន្តំ     អសមំ អសមំ ទទំ ។
សរណំ សរណំ លោកំ     អរណំ អរណំ ករំ
អភយំ អភយំ ឋានំ     នាយកំ នាយកំ នមេ ។

*សូមនមស្ការថ្វាយបង្គំចំពោះព្រះសុគតសាស្តា ដែលយាងទៅកាន់ព្រះនិព្វានជាទីដ៏ក្សេម ទ្រង់ត្រាស់នូវព្រះធម៌ដ៏ប្រសើរកំចាត់កុសលនិងអកុសល ប្រាសចាកមច្ចុ បន្ទុះអមតមហានិព្វាន ជាអ្នកស្ងប់ មិនមានអ្នកណាស្មើបាន ប្រទាននូវព្រះធម៌ ដែលលោកិយធម៌ស្មើមិនបាន ទ្រង់ជាទីពឹងនៃសត្វលោក ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ប្រាសចាកកិលេស ធ្វើនូវការប្រាសចាកកិលេស ជាអ្នកមិនមានភ័យ នាំវេនេយ្យសត្វទៅទីមិនមានភ័យ ជានាយកនៃពួកជន ។*

ពុទ្ធោបិ ពុទ្ធភាវំ     ភាវេត្វា ចេវ សច្ឆិកត្វា ច
យំ ឧបគតោ គតមលំ     វន្ទេ តមនុត្តរំ ធម្មំ ។

*ព្រះពុទ្ធទ្រង់ចម្រើននូវពុទ្ធភាវៈហើយធ្វើឲ្យជាក់*

ច្បាស់នូវព្រះធម៌ឯណា ដែលប្រាសចាកមន្ទិល
ខ្ញុំសូមនមស្ការចំពោះព្រះធម៌ដ៏ប្រសើរនោះ ។

សុគតស្ស ឱរសានំ  ពុត្តានំ មារសេនមថនានំ
អដ្ឋន្នម្បិ សមូហំ  សិរសា វន្ទេ អរិយសង្ឃំ។

ខ្ញុំសូមនមស្ការព្រះអរិយសង្ឃប្រជុំព្រមដោយ ៨ ពួក
ជាឱរសនៃព្រះសុគត ដែលជាអ្នកញាំញីនូវសេនាមារ
ពោលគឺកិលេស ដោយសិរសាគឺត្បូង ។

ឥតិ មេ បសន្នមតិនោ  រតនត្តយវន្ទនាមយំ បុញ្ញំ
យំ សុវិហតន្តរាយោ  ហុត្វា តស្សានុភាវេន។

ដោយអានុភាពនៃបុណ្យកុសលដែលសម្រេចហើយ
ដោយកិរិយានមស្ការប្រជុំបីនៃព្រះរតនត្រ័យ ព្រោះ
សេចក្តីជ្រះថ្លានេះ សូមសីមាពន្ធនវិនិច្ឆ័យបានសម្រេច
ជោគជ័យ សូមអន្តរាយទាំងពួងវិនាសអស់ទៅ ។

## ព្រះពុទ្ធដីកាព្រះភគវន្តមុនីសម្មាសម្ពុទ្ធ

សោ ឯវំ បព្វជិតោ សមានោ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ កាយកម្មវចីកម្មេន សមន្នាគតោ កុសលេន បរិសុទ្ធាជីវោ សីលសម្បន្នោ ឥន្ទ្រិយេសុ គុត្តទ្វារោ សតិសម្បជញ្ញេន សមន្នាគតោ សន្តុដ្ឋោ ។

*លុះបុគ្គលនោះបានបួសយ៉ាងនេះហើយ ក៏សង្រួមតាមបាតិមោក្ខសំវរៈគ្រប់ឥរិយាបថ បរិបូណ៌ដោយអាចារៈនិងគោចារៈ ជាអ្នកឃើញនូវភ័យ ក្នុងទោសទាំងឡាយត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ប្រកបដោយកាយកម្ម និងវចីកម្មជាកុសល មានអាជីវៈបរិសុទ្ធ ជាអ្នកបរិបូណ៌ដោយសីល រក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ប្រកបដោយសតិនិងសម្បជញ្ញៈ ជាអ្នកសន្តោស ។*

*(សុត្តន្តបិដក លេខ ១៤ ទំព័រ ១៥៦ សាមញ្ញផលសូត្រ)*

# សន្ទនាព្រះវិន័យរឿងសីមាកម្ម ជាគ្រាចុងក្រោយ ក្នុង វត្តនិគ្រោធវ័ន (គល់ទទឹង)



# ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន ចូលបួសជាសាមណេរ

# ក្នុងព្រះពុទ្ធសាសនា ខែ មករា ១៩៩៤



# សីមាពន្ធនវិនិច្ឆ័យ

ការសិក្សាក្នុងសីមា ជាប្រយោជន៍ដ៏សំខាន់ដល់ព្រះភិក្ខុនៅក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធនេះ ។ ប្រសិនបើសីមាមានវិបត្តិ ការឧបសម្បទ័ឬសង្ឃកម្មផ្សេង ៗ ក៏មានវិបត្តិផងដែរ ។ អាស្រ័យហេតុនេះ ការសិក្សាពីសីមាត្រូវចាំបាច់ពិនិត្យមើលក្នុងព្រះត្រៃបិដក អដ្ឋកថា ដីកា ឲ្យបានសុក្រឹតជាមុនសិនទើបអំណោយផលល្អដល់អ្នកសិក្សាទាំងឡាយ ។

នៅក្នុងកង្ខាវិតរណី និង វិនយសង្គហដ្ឋកថា (បាលិមុត្តកវិនិច្ឆយ:)

សីមា នាមេសា ពទ្ធសីមា អពទ្ធសីមាតិ ទុវិធា

ហោតិ ។

ឈ្មោះថា សីមា នោះ មានពីរប្រភេទគឺ ពទ្ធសីមា ១ អពទ្ធសីមា ១ ។

សីមាទាំងពីរប្រភេទនេះ សង្ឃអាចធ្វើសង្ឃកម្មទាំងពួងបានដោយមិនជំទាស់ក្នុងកម្មទាំង ៤ គឺ អបលោកនកម្ម ញត្តិកម្ម

ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្មឡើយ ជាសីមាមានសំវាស ស្មើគ្នា មានឧបោសថជាមួយគ្នា ។

ដូចវិនយាលង្ការដីកាថែងថា ៖

សា ច គាមសីមា ពទ្ធសីមាយ រហិតដ្ឋានេ សយមេវ សមានសំវាសា ហោតីតិ ទស្សេតិ ។ ក៏គាមសីមានោះ មាន សំវាសស្មើគ្នាដោយខ្លួនឯងតែម្តង ក្នុងទីប្រាសចាកពទ្ធសីមា ។

តែព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យចង នូវពទ្ធសីមាក្នុងអពទ្ធសីមា (សីមាដែលសង្ឃមិនបានសូធ្យចង) បាន ។ ហេតុនេះ មុននឹងសិក្សាពីពទ្ធសីមាគួរសិក្សាឲ្យល់អិត ក្នុងអពទ្ធសីមាជាខាងដើមជាដំបូងសិន ។

## អពទ្ធសីមា

នៅក្នុងគម្ពីរសមន្តប្បាសាទិកា អដ្ឋកថាមហាវគ្គ វិនយ-សង្គហដ្ឋកថា (បាលិមុត្តកវិនិច្ឆយៈ) និងកង្ខាវិតរណី អដ្ឋកថា បាតិមោក្ខពោលថា ៖

អពទ្ធសីមា បន គាមសីមា សត្តព្ភន្តរសីមា ឧទកុក្ខេបសីមាតិ តិវិធា ។

*ក៏អពទ្ធសីមា មានបីប្រភេទគឺ គាមសីមា ១ សត្តព្ភន្តរ-សីមា ១ ឧទកុក្ខេបសីមា ១ ។*

*សមដូចព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយព្រះសង្គីតិ-កាចារ្យតាំងទុកក្នុងព្រះវិនយបិដកមហាវគ្គ ភាគ ៦ទំព័រ៣៦២ថា៖*

អសម្មតាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ, យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ, យា តស្ស វា គាមស្ស គាមសីមា, និគមស្ស វា និគមសីមា, អយំ តត្ថ សមាន-សំវាសា ឯកុបោសថា ។ អគាមកេ ចេ ភិក្ខវេ អរញ្ញេ សមន្តា សត្តព្ភន្តរា, អយំ តត្ថ សមានសំវាសា ឯកុបោសថា ។ សព្វា ភិក្ខវេ នទី អសីមា, សព្វោ សមុទ្ទោ អសីមោ, សព្វោ ជាតស្សរោ អសីមោ ។ នទិយា វា ភិក្ខវេ សមុទ្ទេ វា

ជាតស្សរេ វា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា,

អយំ តត្ថ សមានសំវាសា ឯកុបោសថា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលទៅអាស្រ័យស្រុកណាក្តី និគមណាក្តី ហើយនៅក្នុងសីមាដែលសង្ឃមិនបានសន្មត មិនបានតាំងទុកហើយ សីមាណាដែលជាគាមសីមារបស់ស្រុកនោះក្តី សីមាណាដែលជានិគមសីមារបស់និគមនោះក្តី សីមានេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងស្រុកឬនិគមនោះ ។ ម្នាលភិក្ខុទាំងឡាយ បើក្នុងព្រៃ មិនមែនស្រុក សីមាដែលកំណត់ ៧ អព្ភន្តរៈដោយជុំវិញ សីមានេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងព្រៃនោះ ។ ម្នាលភិក្ខុទាំងឡាយ ស្ទឹងទាំងអស់មិនមែនជាសីមា សមុទ្រទាំងអស់មិនមែនជាសីមា ជាតស្រះទាំងអស់មិនមែនជាសីមា ។ ម្នាលភិក្ខុទាំងឡាយ ទីណាដែលបុគ្គលកំណត់ ដោយសាចទឹករបស់មជ្ឈិមបុរសដោយជុំវិញក្នុងស្ទឹងក្តី ក្នុងសមុទ្រក្តី ក្នុងជាតស្រះក្តី ទីនេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងទីមានស្ទឹងជាដើមនោះ ។

## ១.គាមសីមា

*អដ្ឋកថា សមន្តបាសាទិកា, អដ្ឋកថា វិនយសង្គហដ្ឋកថា ខែពន្យល់ត្រង់ព្រះពុទ្ធដីកានេះថា ៖*

តត្ថ អដ្ឋបិតាយាតិ អបរិច្ឆិន្នាយ ។ គាមគ្គហណេន ចេត្ថ នគរម្បិ គហិតមេវ ហោតិ ។ តត្ថ យត្តកេ បទេសេ តស្ស គាមស្ស ភោជកា ពលឹ លភន្តិ, សោ បទេសោ អប្បោ វា ហោតុ មហន្តោ វា, គាមសីមាត្វេវ សង្ខ្យំ គច្ឆតិ ។ នគរនិគមសីមាសុបិ ឯសេវ នយោ ។ យម្បិ ឯកស្មឹយេវ គាមក្ខេត្តេ ឯកំ បទេសំ "អយំ វិសុំ គាមោ ហោតូ"តិ បរិច្ឆិន្ទិត្វា រាជា កស្សចិ ទេតិ, សោបិ វិសុំគាមសីមា ហោតិយេវ ។ តស្មា សា ច ឥតរា ច បកតិគាមនគរ-និគមសីមា ពទ្ធសីមាសទិសាយេវ ហោន្តិ, កេវលំ បន តិចីវរវិប្បវាសបរិហារំ ន លភន្តិ ។

បទថា អជ្ឈបិតាយ សេចក្តីថា មិនបានកំណត់ទុក ។ ក៏សូម្បីក្រុងគឺព្រះមានព្រះភាគទ្រង់កាន់យកហើយមែនពិត ក្នុងគាមសីមានិងនិគមសីមានោះ ដោយ គាមសត្ថុ ។ គាមភោជកនៃស្រុកនោះ តែងបាននូវសួយអាករក្នុងប្រទេស (ទីកន្លែង) ប៉ុណ្ណាប្រទេសនោះ តូចក៏ដោយ ធំក៏ដោយ ចូរលើកទុកចុះ រមែងដល់នូវការសង្គ្រោះថា ជាគាមសីមាដូចគ្នា ។ សូម្បីក្នុងនគរសីមានិងនិគមសីមា ក៏មានន័យដូចគ្នា ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់កំណត់នូវប្រទេសមួយក្នុងគាមក្ខេត្តមួយនោះឯងឯណា ឲ្យដល់បុគ្គលណាមួយថា "ទីនេះចូរជាស្រុកផ្សេងចុះ" សូម្បីប្រទេសនោះក៏រមែងជាវិសុំគាមសីមាដែរ ។ ព្រោះហេតុនោះ វិសុំគាម-សីមានោះក្តី បកតិគាមសីមា នគរសីមា និងនិគមសីមាក្រៅនេះក្តី ជាសីមាប្រាកដដូចជាពទ្ធសីមាដែរ ។ តែមិនបានបរិហារការនៅប្រាសចាកត្រៃចីវរ ។

នេះជាសេចក្តីក្នុងអដ្ឋកថា ពន្យល់ពាក្យថា គាមសីមា និងនិគមសីមា ។ តែនៅមិនទាន់ជាក់ច្បាស់នៅឡើយសម្រាប់អ្នកសិក្សាទាំងឡាយ ។ អាស្រ័យហេតុនេះ យើងត្រូវពិចារណាទាំងអស់គ្នា ហើយធ្វើនូវការសិក្សា ។

នៅក្នុងអដ្ឋកថាបាតិមោក្ខ កង្ខាវិតរណីខែថា ៖

តត្ថ យាវតា ឯកំ គាមក្ខេត្តំ, អយំ គាមសីមា នាម ។

គាមក្ខេត្តមួយមានត្រឹមណា គាមក្ខេត្តនេះ ឈ្មោះថា គាមសីមា ។

នៅក្នុងបាចិត្យាទិយោជនាខែពន្យល់ថា ៖

គាមក្ខេត្តិ រញ្ញោ អាណា ចិបិយតិ ឯត្ថាតិ ខេត្តំ, គាមោយេវ ខេត្តំ គាមក្ខេត្តំ ។

ព្រះរាជាទ្រង់លើកនូវអាណាក្នុងទីនោះ ហេតុនោះ ទីនោះ ឈ្មោះថា ខេត្ត, ខេត្តគឺស្រុកនោះឯង ឈ្មោះថា គាមក្ខេត្ត ។

នៅក្នុងគម្ពីរសីមវិសោធនីបាឋៈខែថា ៖

គាមោយេវ គាមសីមា, និគមោយេវ និគមសីមា, នគរមេវ នគរសីមាតិ តាសំ វចនត្ថោ វេទិតព្វោ ។

វចនត្ថៈនៃអពទ្ធសីមានោះ បណ្ឌិតគប្បីជ្រាបដូច្នេះ :

ស្រុកនោះឯង ឈ្មោះថា គាមសីមា, និគមនោះឯង ឈ្មោះថា និគមសីមា, ទីក្រុងនោះឯង ឈ្មោះថា នគរសីមា ។

នៅក្នុងវិមតិវិនោទនីដីកា និងវិនយាលង្ការដីកាខែថា ៖

យា តស្ស គាមស្ស គាមសីមាតិ ឯត្ថ គាម-បរិក្ខេបស្ស អន្តោ ច ពហិ ច ខេត្តវត្ថុអរញ្ញបព្វតាទិកំ សព្វំ គាមក្ខេត្តំ សន្ធាយ "គាមស្សា"តិ វុត្តំ, ន អន្តរឃរមេវ, តស្មា តស្ស សកលស្ស គាមក្ខេត្តស្ស សម្ពន្ធនីយា គាមសីមាតិ ឯវមត្ថោ គហេតព្វោ ។ យោ ហិ សោ អន្តរឃរខេត្តាទីសុ អនេកេសុ ភូមិភាគេសុ "គាមោ"តិ ឯកត្តេន លោកជនេហិ បញ្ញត្តោ គាមវោហារោ, សោវ ឥធ "គាមសីមា"តិបិ វុច្ចតីតិ អធិប្បាយោ ។ គាមោ ឯវ ហិ គាមសីមា ។

បទថា យា តស្ស គាមស្ស គាមសីមា មានសេចក្ដីថា ពាក្យថា គាមស្ស នេះគឺ ព្រះអដ្ឋកថាចារ្យពោលសំដៅយក គាមក្ខេត្តទាំងអស់ មានស្រែ ចម្ការ ព្រៃ ភ្នំជាដើម ទាំងខាងក្នុង

និងខាងក្រៅនៃស្រុកដែលឡោមព័ទ្ធ, មិនមែនក្នុងចន្លោះនៃផ្ទះទេ, ព្រោះហេតុនោះ គាមសីមា ជាសីមាដែលជាប់ទាក់ទងនូវគាមក្ខេត្តទាំងមូល ។ គាមវោហារដែលលោកជនទាំងឡាយបញ្ញត្តដោយចំណែកមួយថា "ស្រុក" ក្នុងភូមិភាគដ៏ច្រើន មានចន្លោះផ្ទះនិងស្រែជាដើម ។ គាមវោហារនោះឯង គឺអដ្ឋកថាចារ្យហៅ សូម្បីថា គាមសីមា ដូច្នេះ ។ មែនពិតស្រុកនោះឯង ឈ្មោះថា គាមសីមា ។

គាមសីមានេះសំដៅទៅលើស្រុកទីមួយ ៗ ។

តើគាមសីមា ក្នុងកាលសព្វថ្ងៃនេះ ជាស្រុកឬជាឃុំ ?

តាមការសិក្សា ឃើញមានពាក្យប្រើថា គាមភោជកក្នុងអដ្ឋកថានិងដីកាគ្រប់កន្លែង ។ ដូច្នេះ គាមភោជក មានន័យថា មេស្រុក គឺមេឃុំ ។ ពាក្យថា ឃុំ អាចជាពាក្យក្លាយពីពាក្យថា គម ឬគាម ដែលប្រែថា ស្រុក ។ កាលពីសម័យបុរាណកាលគ្រប់គ្រងរដ្ឋក្នុងស្រុកខ្មែរយើង មាននាវមួយហៅ មេស្រុក

ឬហៅថា គាមភោជក នេះសំដៅទៅលើមេឃុំយើងសព្វថ្ងៃនេះឯង ។

ដូចនៅក្នុងវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ អភិ-ធជមហារដ្ឋគុរុ អគ្គបណ្ឌិត ជោតញ្ញាណោ ជួន ណាត បោះពុម្ពលើកទី ៥ ព.ស.២៥១១ គ.ស.១៩៦៧ ទំព័រ ១៣៣ បាន រំគាយសេចក្ដីថា គាមភោជក (គាមៈភោជក់) ន. (បា., សំ. គ្រាមភោជក "មេស្រុក" ។ មហាគាមភោជក "ចៅហ្វាយស្រុក"។

កាលពីសម័យមុនប្រទេសយើងតែងហៅមេឃុំថា "មេស្រុក"ឬ គាមភោជក ។ តែងហៅចៅហ្វាយស្រុកថា "លោកចៅហ្វាយ"ឬ "ចៅហ្វាយស្រុក" ។

បើ គាមសីមា ជាឃុំ តើនិគមជាសីមាអ្វីដែរ ?

ជា និគមសីមា ។ ព្រោះនិគមមានន័យថា ការប្រជុំរួមរបស់ស្រុកគឺមានស្រុកជាច្រើន ដូចនៅក្នុងគម្ពីរអភិធានប្ប-

ទីបិកាដីកាខែថា អតិរេកោ គាមោ និគមោ ស្រុកជាច្រើន ឈ្មោះថា និគម ។

នៅក្នុងឧត្តរវិនិច្ឆយដីកា ឈ្មោះ វិនយត្ថសារសន្ទីបនីខែថា និគមោ ឆាម សាបណោ មហាគាមោ ស្រុកធំដែលមានផ្សារ ឈ្មោះថា និគម ។

នៅក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ឈ្មោះ វិនយត្ថមញ្ជូសាខែថា អចាការបរិក្ខេបោ សាបណោ និគមោ និគមមានផ្សារមិនមានរបងឡោមព័ទ្ធដូចទីក្រុងទេ ។

ដូច្នេះ គាម បានដល់ ឃុំ សង្កាត់ ។ និគម បានដល់ស្រុកជាច្រើនស្ថិតនៅក្រោមអ្នកណាមួយត្រួតត្រា ។

សរុបសេចក្តីមកនៅក្នុងស្រុកមួយ មានឃុំប៉ុន្មាន ទ្បីរួមស្រុកនោះ មានគាមសីមាប៉ុណ្ណោះ ។

<u>ឧទាហរណ៍</u> ស្រុកអូរាំងឪ មានឃុំ ១៦ ដូច្នេះ គាមសីមាមាន ១៦ ដែរ ។

# វិសុំគាមសីមា

*តើវិសុំគាមសីមា មានលក្ខណៈយ៉ាងណាទៅវិញ ?*

*គួរសង្កេតមើលក្នុងអដ្ឋកថាឲ្យច្បាស់ត្រង់ពាក្យថា ៖*

យស្មិំ ឯកស្មិំយេវ គាមក្ខេត្តេ ឯកំ បទេសំ "អយំ វិសុំគាមោ ហោតូ"តិ បរិច្ឆិន្ទិត្វា រាជា កស្សចិ ទេតិ, សោបិ វិសុំគាមសីមា ហោតិយេវ ។ តស្មា សា ច ឥតរា ច បកតិគាមនគរនិគមសីមា ពទ្ធសីមាសទិសាយេវ ហោន្តិ ។

*ម្យ៉ាងទៀត ព្រះរាជាទ្រង់កំណត់នូវប្រទេសមួយក្នុងគាមក្ខេត្តមួយនោះឯងឯណា ឲ្យដល់បុគ្គលណាមួយថា "ទីនេះចូរជាស្រុកផ្សេងចុះ" សូម្បីប្រទេសនោះក៏រមែងជាវិសុំគាមសីមាដែរ ។ ព្រោះហេតុនោះ វិសុំគាមសីមានោះក្តី បកតិគាមសីមា នគរសីមា និងនិគមសីមាក្រៅនេះក្តី ជាសីមាប្រាកដដូចជាពទ្ធសីមាដែរ ។*

*កាលពិនិត្យមើលឃើញថា វិសុំគាមសីមា ក៏គឺគាមសីមានេះឯង ព្រោះព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យដល់បុគ្គលណា*

មួយ ទ្រង់ក៏ឲ្យទីនោះ ដល់អ្នកនោះ គ្រាន់បានទទួលសួយអាករពីស្រុកនោះឯង ។ អ្នកដែលទទួលយកគ្រាមពីព្រះរាជា មានឈ្មោះថា គាមភោជកដែរ ទើបទីនោះ គួរដល់សង្ឃកម្មទាំងពួងដូចគាមសីមា ។ កាលពុទ្ធសម័យក្នុងស្រុកនីមួយ ៗ ត្រូវបង់ពន្ធដារដល់ព្រះរាជា តែពេលព្រះរាជាទ្រង់ពេញចិត្តអ្នកណាមួយ ទ្រង់ក៏បង្វិលពន្ធដារពីស្រុកនោះ ដល់មនុស្សដែលទ្រង់ពេញចិត្ត ដូចនាយមាលាការដែលព្រះរាជាទ្រង់ពេញចិត្ត ប្រគល់សួយអាករឲ្យ ទីដែលនាយមាលាការបានសួយអាករនោះ ទីនោះឈ្មោះថា គាមសីមាខ្វះ វិសុំគាមសីមាផ្សេងពីស្រុកមុនខ្វះ ។

ហេតុដូច្នេះបានជាគម្ពីរបាចិត្យាទិយោជនាខែសង្កត់ថា ៖

សោបិ វិសុំគាមោ គាមសីមា ហោតិយេវ ។

សូម្បីវិសុំគាមនោះ ជាគាមសីមានេះឯងដែរមែនពិត ។ វិសុំ

បរិច្ឆិន្ទិត្វា ទិន្នោ គាមោ វិសុំគាមោ ។ ស្រុកផ្សេង ដែល

ព្រះរាជាទ្រង់កំណត់ឲ្យដល់គាមភោជក ឈ្មោះថា វិសុំគាម ។

កាលបើពិចារណានៅក្នុងយោជនានេះ ព្រះអដ្ឋកថាចារ្យយក អបិសទ្ទ មកភ្ជាប់ជាមួយពាក្យថា សោ មានន័យថា សូម្បី

រីវិសុំគាមសីមានោះ ដូចយោជនាថា សោបិតិ បទេសោបិ ។ វិសុំគាមោ នាមាតិ យោជនា ។ សោបិ វិសុំគាមោ គាមសីមា ហោតិយេវាតិ យោជនា ។ ពាក្យថា សោបិ បានន័យថា សូម្បីប្រទេសនោះ ។ យោជនាថា ឈ្មោះថា វិសុំ-គាម ។ យោជនាដូច្នេះថា សូម្បីវិសុំគាមសីមានោះ ជាគាម-សីមាដែរមែនពិត ។

អបិ–និបាតសព្ទ ចុះក្នុងអត្ថថា អបេក្ខត្ថៈ "អត្ថដែលសំឡឹង" ទៅក្នុងនាមដែលជាសេចក្តីខាងដើម គឺសេចក្តីដែលអដ្ឋកថាចារ្យពន្យល់ពាក្យថា គាមសីមានោះ ។ សេចក្តីបន្ទាប់អដ្ឋកថាចារ្យលើកយកនាមមួយបញ្ចាក់ហើយភ្ជាប់ដោយ អបិ-សព្ទ ដូចពាក្យថា សោបិ មកភ្ជាប់ជាមួយ វិសុំគាមោ បានន័យថា សូម្បីវិសុំគាមនោះ ។ យោជនាសង្កត់ធ្ងន់ដោយន័យដដែលបីជង ទី ១ លើកពាក្យមកថា សោ បទេសោបិ សូម្បីប្រទេសនោះ ។ ទី ២ បទេសោបិ វិសុំគាមោ នាម សូម្បី

ប្រទេសនោះឈ្មោះថា វិសុំគាម ។ ទី ៣ សោបិ វិសុំគាមោ គាមសីមា ហោតិយេវា សូម្បី វិសុំគាម នោះជា គាម–សីមាដែរមែនពិត ។

តាមន័យក្នុងយោជនាបញ្ជាក់យ៉ាងច្បាស់ ទាំងក្នុងនិបាត ដែលជា អបិ–សព្ទ និងសេចក្តីនៃវិសុំគាមសីមា ។ តែមកពី យើងមិនសិក្សារៀនសូធ្យ ទើបអាច...។

យើងសិក្សាបន្ថែមទៀតត្រង់អដ្ឋកថាពោលថា ៖

តស្មា សា ច ឥតរា ច បកតិគាមនគរនិគមសីមា ពទ្ធសីមាសទិសាយេវ ហោន្តិ ។ ព្រោះហេតុនោះ វិសុំគាមសីមា នោះក្តី បកតិគាមសីមា នគរសីមា និងនិគមសីមាក្រៅនេះក្តី ជាសីមាប្រាកដដូចជាពទ្ធសីមាដែរ ។

នៅក្នុងគម្ពីរវជិរពុទ្ធិដីកាខែថា ៖

សា ចាតិ សា បរិច្ឆិន្ទិត្វា ទិន្នគាមសីមា ច ឥតរា ច ។ បទថា សា ច សេចក្តីថា គាមសីមាដែលព្រះរាជាទ្រង់

កំណត់ឲ្យដល់គាមកោជកនោះក្តី បកតិគាមសីមា នគរសីមា និងនិគមសីមាក្រៅនេះក្តី ។

ទីនេះ អដ្ឋកថា សមន្តបាសាទិកា ប្រើពាក្យថា បកតិ-គាមសីមា មានន័យថា គាមសីមាតាមប្រក្រតីដោយការកំណត់ស្រុកជុំវិញទាំងមូលដោយខ្លួនឯង មិនបានកើតឡើងដោយការកំណត់ណាមួយឡើយ ។ អាស្រ័យពាក្យនេះ បានជាគម្ពីរដីកាជាច្រើន ហៅ វិសុំគាមសីមា ថា អភិនវគាមសីមា ហៅថា បកតិគាមសីមា ថា បុរាណគាមសីមា ខ្វះ ថា បកតិគាម-សីមា ខ្វះ ។ ដូចមានបាលីត្រង់គម្ពីរវិនយាលង្ការដីកាបញ្ជាក់ថា បុរាណគាមសីមា ច អភិនវគាមសីមា ច ។

ថែមទាំងនៅក្នុងគម្ពីរវិមតិវិនោទនីដីកាខែថា ៖

តត្ថ ហិ សា ច រាជិច្ឆាវសេន បរិវត្តិត្វា សមុប្បន្នា អភិនវា, ឥតរា ច អបរិវត្តា បកតិគាមសីមា, យថា ពទ្ធសីមាយ សព្វំ សង្ឃកម្មំ កាតុំ វដ្ដតិ, ឯវមេតាបិ

សព្ពកម្មារហាតាសទិសេន ពទ្ធសីមាសទិសា, សា សមាន–សំវាសា ឯកូបោសថាតិ អធិប្បាយោ ។ មែនពិតសេចក្តីអធិប្បាយក្នុងបទនោះថា វិសុំគាមសីមា ជាសីមាកើតឡើងថ្មី ព្រោះការផ្លាស់ប្តូរដោយអំណាចនៃសេចក្តីប្រាថ្នារបស់ព្រះរាជាក្តី បកតិគាមសីមា ដែលមិនផ្លាស់ប្តូរក្រៅនេះក្តី គួរដល់សង្ឃកម្មទាំងពួង ដូចពទ្ធសីមាដែរ, សូម្បីសីមាទាំងនោះឯង ប្រាកដដូចពទ្ធសីមា ដោយការប្រាកដគួរដល់សង្ឃកម្មទាំងពួង, សីមានោះមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។

នៅក្នុងគម្ពីរវិនយាលង្ការដីកាថា ៖

"យស្មិំ ឯកស្មិំយេវ គាមក្ខេត្តេ ឯកំ បទេសំ, អយំ វិសុំគាមោ ហោតូតិ បរិច្ឆិន្ទិត្វា រាជា កស្សចិ ទេតិ, សោបិ វិសុំគាមសីមា ហោតិយេវា"តិ អដ្ឋកថាយំ វចនតោ រាជា "បកតិគាមក្ខេត្តេយេវ បកតិគាមតោ វិសុំ បកតិគាមេន អសម្មិស្សោ គាមោ ហោតូ"តិ យំ បទេសំ ទេតិ, សោ បទេសោ វិសុំគាមសីមា នាម ។

ព្រះរាជាទ្រង់កំណត់ប្រទេសឯណាថា “ ស្រុកនេះ ចូរជាស្រុកដែលមិនលាយដោយស្រុកប្រក្រតី ផ្សេងពីស្រុកប្រក្រតីក្នុងបកតិគាមក្ខេត្តនោះឯង” ដូច្នេះ ប្រទេសនោះ ឈ្មោះថា វិសុំគាមសីមា ព្រោះពាក្យក្នុងអដ្ឋកថាថា “ម្យ៉ាងទៀត ព្រះរាជាទ្រង់កំណត់នូវប្រទេសមួយក្នុងគាមក្ខេត្តមួយនោះឯងឯណា ឲ្យដល់បុគ្គលណាមួយថា ទីនេះចូរជាស្រុកផ្សេងចុះ សូម្បីប្រទេសនោះក៏រមែងជាវិសុំគាមសីមាដែរ” ។

ឥតិ បកតិគាមសីមា ច រាជូនំ ឥច្ឆាវសេន បវត្តា វិសុំគាមសីមា ច ពទ្ធសីមា វិយ សព្វកម្មារហា, តស្មា អភិនវពទ្ធសីមំ ពន្ធិតុកាមេហិ បកតិគាមសីមំ វា វិសុំ-គាមសីមំ វា សោធេត្វា កត្តព្វំ ហោតិ ។

ដោយប្រការដូច្នេះ បកតិគាមសីមាក្តី វិសុំគាមសីមាដែលប្រព្រឹត្តទៅ ដោយអំណាចនៃសេចក្តីប្រាថ្នារបស់ព្រះរាជាទាំងឡាយក្តី គួរដល់សង្ឃកម្មទាំងពួង ដូចពទ្ធសីមាដែរ, ព្រោះ

ហេតុនោះ ភិក្ខុទាំងឡាយដែលប្រាថ្នាចងនូវពទ្ធសីមាថ្មី គប្បីជម្រះ(គឺនាំភិក្ខុមកកាន់ហត្ថបាសឬនាំធនុះ) ហើយធ្វើចុះ ។

សរុបសេចក្ដី វិសុំគាមសីមា ក៏គឺគាមសីមានោះឯង គ្រាន់តែកើតឡើងដោយអំណាចនៃការផ្លាស់ប្ដូររបស់ព្រះរាជា ។ មានការយល់ជាច្រើនថា "ទីដីដែលព្រះរាជាប្រទានឲ្យវត្ត ឬមន្ត្រីរាជការ អាជ្ញាធរធ្វើប្លង់ប្រគល់ឲ្យមកវត្ត ទីនោះ ជាវិសុំគាមសីមា ។ កាលសង្ឃចងសីមាត្រូវនិមន្តត្រឹមភិក្ខុដែលនៅក្នុងវត្តនោះប៉ុណ្ណោះមកកាន់ហត្ថបាសបានហើយ មិនចាំបាច់និមន្តភិក្ខុនៅខាងក្រៅវត្តមកទេ ។ ព្រោះទីដីក្នុងវត្តនេះ ជាវិសុំគាមសីមាស្រេច ។ កាលយល់ដូច្នេះហើយ ក៏ធ្វើការដកសីមា និងចងសីមា ។

តាមការណ៍ពិត លក្ខណៈវិសុំគាមសីមា មិនមែនដូច្នេះទេ ។ លក្ខណៈវិសុំគាមសីមា គឺស្រុកដែលព្រះរាជាទ្រង់កំណត់ឲ្យដល់គាមភោជកទទួលយកសួយអាករ ឲ្យបានជាធំក្នុងស្រុកនោះ ។ ដូចក្នុងគម្ពីរវិនយាលង្ការដីកាខែថា ៖ ពាក្យក្នុងអដ្ឋកថាថា "អយំ វិសុំគាមោ ហោតុ" មានន័យថា ព្រះរាជាទ្រង់

ធ្វើស្រុកមួយឲ្យទៅជាស្រុកពីរ ។ មានបាលីអាងថា ឯកំយេវ គាមក្ខេត្តំ ទ្វេ គាមេ ករោតីតិ ឧស្សេតិ ។ ចំណែកពាក្យថា រាជា កស្សចិ ទេតិ មានន័យថា ទ្រង់ឲ្យដល់គាមភោជក ។ មានបាលីអាងថា គាមភោជកស្ស ទិន្នភាវំ បកាសេតិ ។

ដូច្នេះ លក្ខណៈវិសុំគាម ក្នុងអដ្ឋកថាមានពីរគឺ ទ្រង់ធ្វើស្រុកមួយឲ្យទៅជាស្រុកពីរ ១ ប្រគល់ឲ្យគាមភោជក ១ ។

ឧទាហរណ៍ ក្នុងឃុំគងជ័យ ជាឃុំមួយតែឯងដាច់ពីឃុំផ្សេង ៗ មានគាមភោជក (មេស្រុក)មួយនាក់គ្រប់គ្រងឃុំនោះ ពេលនោះព្រះរាជាទ្រង់ពេញចិត្តអ្នកណាមួយហើយប្រទានឲ្យថា ទឹកដីមានប៉ុណ្ណេះហិចតា អ្នកឯងចូរយកពន្ធដារស្ឌយអាករចុះ ។ ទឹកដីមានប៉ុណ្ណោះហិចតាក្នុងឃុំគងជ័យ បានលើបុគ្គលនោះគ្រប់គ្រងទៅ បុគ្គលអ្នកដែលព្រះរាជាប្រទានឲ្យនោះ មានឈ្មោះថាជាគាមភោជកលើដីប៉ុណ្ណោះឯង ។ ដូច្នេះ កាលពីមុន ឃុំគងជ័យជាគាមក្ខេត្តតែមួយទេ ដល់ព្រះរាជាប្រទានឲ្យដល់បុគ្គលណាមួយ ឃុំនោះ ទៅជាស្រុកពីរ ទឹកដីដែលគ្រប់គ្រងដោយ

គាមកោជកចាស់ មានឈ្មោះថា បកតិគ្រាម ។ ទីកដីដែលគ្រប់គ្រងដោយគាមកោជក ដែលព្រះរាជាប្រទានឲ្យ មានឈ្មោះថា វិសុំគ្រាម ។ យ៉ាងនេះ ជា វិសុំគាមលក្ខណៈ ។ នៅក្នុងការប្រគល់ឲ្យនេះទៀតសោត មិនមែនឲ្យដីដាច់ទេ គឺឲ្យយកពន្ធដារសួយអាករពីទីដីនោះ ដូចមានក្នុងព្រះត្រៃបិដក និងអដ្ឋកថាជាច្រើន ដែលព្រះរាជាសម័យនោះ ប្រគល់ឲ្យអ្នកណាម្នាក់ទទួលយកសួយអាករ ។ ដូចនៅក្នុងអដ្ឋកថាធម្មបទ ពាលវគ្គ សុមន-មាលាការវត្ថុមានសំដែងថា ព្រះបាទពិម្ពិសារទ្រង់ជ្រះថ្លានឹងនាយមាលាការព្រះអង្គក៏ទ្រង់ប្រទានស្រុកដ៏ប្រសើរ ៨ ដល់គាត់ដើម្បីទទួលយកសួយអាករពីស្រុកនោះ មានបាលីអាងថា អដ្ឋគាមវរេ ទ្រង់ប្រទានស្រុកដ៏ប្រសើរ ៨ ដល់មាលាការ ។ តែក្នុងទីគាមក្ខេត្តដែលព្រះរាជាទ្រង់ប្រទានឲ្យនេះ ឲ្យស្រុកទាំងប្រាំបីតែម្ដង ដូច្នេះគាមក្ខេត្តទាំងអស់ មាន ៨ ដែលនាយមាលាការគាត់ជាគាមកោជកគ្រប់គ្រង ដូច្នេះទីនេះ ឈ្មោះថាមាន គាមសីមា ៨ ។ ប្រសិនបើទ្រង់ប្រទានឲ្យត្រឹមមួយចំណែក ក្នុងគាមក្ខេត្តមួយវិញ

មួយចំណែកដែលទ្រង់ប្រទាននោះ ជាវិសុំគាមសីមា ។ តែចំពោះការប្រទានដីឲ្យមានលក្ខណៈដូចគ្នា ។

សូមមើលក្នុងគម្ពីរសីមវិសោធនីបាឋៈបន្ថែមទៀតផង ។

នៅក្នុងវិនយាលង្ការដីកាសង្កត់ធ្ងន់ថែមទៀតថា ៖

តស្មា បដិស្សុតេ រាជា ឥមស្មឹ គាមក្ខេត្តេ ឯត្តកករីសមត្តោ បទេសោ បុរិមគាមតោ វិសុំគាមោ ហោតូតិ បរិច្ឆិន្ទិត្វា ទេតិ, ឯត្តាវតា សោ បទេសោ ពលឹ បដិគ្គាហិកោ វា ហោតុ អប្បដិគ្គាហិកោ វា, វិសុំគាមោ នាម ហោតិ ។

ព្រោះហេតុនោះ ព្រះរាជាទ្រង់ជាធំលើផែនដីកំណត់ឲ្យដល់បុគ្គលណាមួយថា "ប្រទេសត្រឹមករីសៈប៉ុណ្ណេះ ចូរជា វិសុំគាមផ្សេងពីស្រុកមុនចុះ"ដូច្នេះ ប្រទេសត្រឹមប៉ុណ្ណោះនោះ គឺគាមភោជកបានទទួលសួយអាករក៏ដោយ មិនបានទទួលក៏ដោយ ឈ្មោះថា ជាវិសុំគាមពិត ។

បាលីត្រង់ ឯត្តាវតា សោ បទេសោ ពលឹ បដិគ្គាហិកោ វា ហោតុ អប្បដិគ្គាហិកោ វា, វិសុំគាមោ នាម ហោតិ គួរ

យើងសិក្សាមើលថា តើព្រះរាជាទ្រង់ប្រគល់ឲ្យដល់អ្នកណា តើហេតុអ្វីបានជាកាចារ្យហៅទីនេះថាវិសុំគាម ។

មានព្រះភិក្ខុអង្គខ្លះមានបំណងចងពទ្ធសីមាថ្មី ក៏សូមឲ្យព្រះរាជាប្រទានដីឲ្យ ឬមន្ត្រីរាជការ អាជ្ញាធរប្រគល់ប្ល័ង់ដីឲ្យ ។ បន្ទាប់មកក៏ធ្វើការចងពទ្ធសីមា ដោយសំគាល់ថា ដីវត្តនេះ ជាវិសុំគាមសីមា និមន្តត្រឹមតែភិក្ខុនៅក្នុងទីដីវត្តមកកាន់ហត្ថបាស ឬនាំឆន្ទៈ តែមិនបាននិមន្តភិក្ខុដទៃខាងក្រៅមកទេ ហើយប្រកាសថា "អយំ ភូមិប្បទេសោ វិសុំ គាមោ ហោតុ ភូមិប្រទេសនេះ ចូរជាទីផ្សេងចាកស្រុកចុះ" ហើយធ្វើការដកសីមានិងចងសីមា ។

ការធ្វើយ៉ាងនេះ មានបរិសវិបត្តិ (មានកម្មជាពួក) ព្រោះដីវត្តនេះ មិនមែនជាវិសុំគាមសីមា ។ ព្រោះលក្ខណៈដែលព្រះរាជាទ្រង់ប្រទានឲ្យក៏ដោយ មន្ត្រីរាជការ អាជ្ញាធរប្រគល់ឲ្យក៏ដោយ ដីនោះនៅតែជាគាមសីមា ។ ព្រោះ វិសុំគាម-លក្ខណៈមិនមែនដូច្នេះ ។

*ដូចនៅក្នុងវិនយាលង្ការដីកាពន្យល់ ពីភិក្ខុខ្លះចូលទៅសុំដីព្រះរាជាចងពទ្ធសីមាថា ៖*

កេចិ បន អាចរិយា "មយំ សីមំ ពន្ធិតុកាមា, តស្មា ឯត្តកោ ភូមិបរិច្ឆេទោ វិសុំខេត្តំ ហោតូ"តិ រាជានំ អាបុច្ឆិត្វា តេន ឱកាសេ កតេ "ឥទំ ឋានំ វិសុំគាមក្ខេត្តំ ហោតី"តិ មនសិ កត្វា តត្រដ្ឋេយេវ ភិក្ខូ ច ហត្ថចាសានយនាទិនា សោធេត្វា សីមាសមូហនសីមាពន្ធនាទីនិ ករោន្តិ។

*ក៏អាចារ្យពួកខ្លះ សុំដីព្រះរាជាថា "បពិត្រមហារាជ អាត្មាទាំងឡាយ មានបំណងចងនូវសីមា ព្រោះហេតុនោះ សូមមហា-បពិត្រកំណត់នូវដីត្រឹមប៉ុណ្ណោះឲ្យជាវិសុំខេត្ត(វិសុំគាម)ចុះ" កាលព្រះរាជាប្រទានឲ្យហើយក៏ធ្វើទុកក្នុងចិត្តថា "ទីនេះជាវិសុំគាមក្ខេត្ត" ហើយជម្រះនូវភិក្ខុទាំងឡាយ ដែលស្ថិតនៅក្នុងទីដីនោះឯង ដោយន័យមានការនាំមកកាន់ហត្ថបាសជាដើម ហើយធ្វើនូវការដកសីមា និងការចងសីមាជាដើម ។*

តំ ការណំ "អយំ វិសុំគាមោ ហោតូតិ បរិច្ឆិន្ទិត្វា រាជា កស្សចិ ទេតី"តិ អដ្ឋកថាវចនេន,"សា ច រាជិច្ឆាវសេន បរិវត្តិត្វា សមុប្បន្នា អភិនវា ចា"តិ អាគតេន វិមតិវិនោទនីដីកាវចនេន ច សមេន្តំ វិយ ន ទិស្សតិ ។

*បានជាអាចារ្យទាំងនោះចូលទៅសុំដីព្រះរាជាឲ្យទ្រង់កំណត់ឲ្យដោយអាងពាក្យក្នុងអដ្ឋកថាថា* "អយំ វិសុំគាមោ ហោតូតិ បរិច្ឆិន្ទិត្វា រាជា កស្សចិ ទេតិ" *ដូច្នេះ និងអាងពាក្យក្នុងគម្ពីរវិមតិវិនោទនីដីកាថា*"សា ច រាជិច្ឆាវសេន បរិវត្តិត្វា សមុប្បន្នា អភិនវា ច" *ដូច្នេះ តែការអាងរបស់អាចារ្យទាំងនោះមិនត្រូវទំនងក្នុងអដ្ឋកថានិងដីកាសោះ ។*

កថំ ? អដ្ឋកថាវចនេ តាវ "អយំ វិសុំគាមោ ហោតូ"តិ ឥមិនា ន កេវលំ បុរិមគាមោយេវ គាមោ ហោតុ, អថខោ ឥទានិ បរិច្ឆិន្នបទេសោបិ វិសុំយេវ គាមោ ហោតូតិ

ឯកំយេវ គាមក្ខេត្តំ ទ្វេ គាមេ ករោតីតិ ឧស្សេតិ ។"រាជា កស្សចិ ទេតី"តិ ឥមិនា គាមភោជកស្ស ទិន្នភាវំ បកាសេតិ ។

*តើមិនត្រូវទំនងយ៉ាងណាទៅ ? គប្បីសិក្សាក្នុងពាក្យអដ្ឋកថាជាមុនសិនត្រង់ពាក្យថា "អយំ វិសុំគាមោ ហោតុ" នេះជាស្រុកមិនមែនស្រុកក្នុងកាលមុន, តាមពិតទៅ សូម្បីប្រទេសដែលបានកំណត់ហើយជាស្រុកផ្សេងពីស្រុកមុនមែនពិត ដូច្នេះតែអដ្ឋកថាសំដែងឲ្យឃើញថា ធ្វើគាមក្ខេត្តមួយនោះឯង ឲ្យទៅជាស្រុកពីរ ។ ឥឡូវសិក្សាត្រង់ពាក្យថា "រាជា កស្សចិ ទេតិ" នេះ អដ្ឋកថាចារ្យប្រកាសនូវភាវៈនៃស្រុកដែលព្រះរាជាទ្រង់ប្រទានឲ្យដល់គាមភោជក ។*

ឥធ បន នេវ ទ្វេ គាមេ ករោតិ, ន ច គាមភោជកស្ស ទេតិ, កេវលំ ភិក្ខូនំ អនុមតិយា យាវកាលិកវសេនេវ ឱកាសំ ករោតិ, ឯវំ អដ្ឋកថាវចនេនបិ សមេន្តំ វិយ ន ទិស្សតិ ។

*ចំណែកក្នុងទីដែលអាចារ្យខ្លះ (សំដៅទៅលើព្រះភិក្ខុ) ចូលទៅសុំព្រះរាជានេះ មិនមែនធ្វើគាមក្ខេត្តមួយឲ្យទៅជាស្រុកពីរពិតប្រាកដ, ហើយក៏មិនមែនប្រទានឲ្យដល់គាមភោជកដែរ,*

កាលព្រះរាជាធ្វើឱកាសកំណត់ឲ្យ ដោយត្រឹមតែកាលប្រព្រឹត្ត ទៅនៃការអនុម័តិរបស់ភិក្ខុទាំងឡាយតែម្យ៉ាង, ដោយប្រការ យ៉ាងនេះ បានជាភិក្ខុទាំងឡាយចូលទៅសុំដីព្រះរាជាឲ្យទ្រង់ កំណត់ឲ្យ មិនត្រូវទំនងសោះ សូម្បីពាក្យមានមកក្នុងអដ្ឋកថា ។

វិមតិវិនោទនីដីកាវចនេនបិ "រាជិច្ឆាវសេន បរិវត្តិត្វា"តិ ឥមិនា អគាមភូតំ ខេត្តំ រាជិច្ឆាវសេន បរិវត្តិត្វា គាមោ ហោតីតិ ទស្សេតិ។

និងមិនត្រូវទំនងសោះ សូម្បីពាក្យក្នុងវិមតិវិនោទនីដីកា ត្រង់ពាក្យថា "រាជិច្ឆាវសេន បរិវត្តិត្វា" នេះ សំដែងថា ជាស្រុក ព្រោះការផ្លាស់ប្តូរនូវខេត្តមិនមែនជាស្រុក ដោយអំណាចនៃ សេចក្តីប្រាថ្នារបស់ព្រះរាជា ។

"អភិនវា ចា"តិ ឥមិនា បុរាណគាមសីមា ច អភិនវ–គាមសីមា ចាតិ បុរិមគាមេន អមិស្សំ វិសុំគាមលក្ខណំ ទស្សេតិ។

តាមពិតពាក្យត្រង់វិមតិវិនោទនីដីកាថា "អភិនវា ច" នេះ តែងសំដែងនូវវិសុំគាមលក្ខណៈ ដែលមិនលាយឡំដោយស្រុកមុនគឺ បុរាណគាមសីមា ១ អភិនវគាមសីមា ១ ។

ឥធ បន រាជិច្ឆាវសេន បរិវត្តិត្វា ខេត្តស្ស វិសុំគាម-ភូតភាវញ្ច អភិនវភាវេន វិសុំគាមលក្ខណញ្ច ន ទិស្សតិ, ឯវំ ដីកាវចនេនបិ សមេន្តុំ វិយ ន ទិស្សតិ។

ចំណែកក្នុងទីដែលភិក្ខុទាំងឡាយចូលទៅសុំដីព្រះរាជានេះ តែងមិនប្រាកដនូវភាវៈនៃខេត្តជាវិសុំគាម ព្រោះការផ្លាស់ប្តូរដោយអំណាចនៃសេចក្តីប្រាថ្នារបស់ព្រះរាជាផង នូវវិសុំគាមលក្ខណៈដោយភាវៈជាស្រុកថ្មីផង, ដោយប្រការដូច្នេះឯង កាលភិក្ខុទាំងឡាយចូលទៅសុំដីឲ្យទៅជាវិសុំគាមនេះ មិនត្រូវទំនងសោះនូវពាក្យមានមកក្នុងដីកាចារ្យ ។

កាលសិក្សាយ៉ាងល្អិតក្នុងអដ្ឋកថា ដីកា ដើម្បីកុំឲ្យយើងយល់ច្រឡំខុសពីពុទ្ធានុញ្ញាត ដែលព្រះអង្គទ្រង់អនុញ្ញាតហើយ ព្រោះការសិក្សាមិនល្អ អាចនាំឲ្យមានវិបត្តិក្នុងការចងសីមាបាន ដូចយល់ច្រឡំថា "ទីដីដែលព្រះរាជាទ្រង់ប្រទានកំណាត់ឲ្យ ឬ

មន្ត្រីរាជការ អាជ្ញាធរធ្វើប្លង់វត្តប្រគល់មកវត្ត ជាវិសុំគាមសីមា” ពេលនោះ ក៏នាំគ្នាចងសីមាដោយត្រឹមនាំភិក្ខុនៅក្នុងវត្តមកកាន់ហត្ថបាស ដោយសំគាល់ថា ទីដីនោះជាវិសុំគាម ។ កាលចងសីមាក៏មានវិបត្តិទៅ ព្រោះដីនោះ នៅតែជាគាមសីមាដដែល ។ ហេតុអ្វីបានមានវិបត្តិ ? ព្រោះមិនបាននិមន្តភិក្ខុដែលនៅក្នុងឃុំទាំងមូលមកជួបជុំក្នុងហត្ថបាស កម្មជាពួក ។ ធម្មតាឃុំទាំងមូលជាគាមសីមា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ព្រោះជាអពទ្ធសីមា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតហើយ។ ដូច្នេះ កាលធ្វើសង្ឃកម្មណាទីមួយក៏ដោយ ដូចជាសង្ឃកម្មចងសីមានេះជាដើម ត្រូវនិមន្តភិក្ខុទាំងអស់នៅក្នុងគាមសីមាជាមួយគ្នាមកកាន់ហត្ថបាស បើមិនដូច្នោះទេ ត្រូវនាំឆន្ទៈមក ឬត្រូវកំណត់ពេលឲ្យភិក្ខុនៅក្នុងឃុំនោះទាំងអស់ ចូលទៅកាន់ពទ្ធ-សីមាដែលសង្ឃបានចងយ៉ាងត្រឹមត្រូវហើយ ។ កាលធ្វើយ៉ាងនេះ **ទើបសង្ឃកម្ម ឈ្មោះថា មានបរិសសម្បត្តិ** ។

កាលយល់ខុសនូវគាមសីមា និង វិសុំគាមសីមាទាំងពីរនេះហើយ កាលចងពទ្ធសីមាក៏មិនត្រឹមត្រូវឡើយ ព្រោះពទ្ធសីមា ត្រូវចងអាស្រ័យគាមសីមា និងវិសុំគាមសីមា ។

# ២.សត្តព្ភន្តរសីមា

*នៅក្នុងវិនយសង្គហដ្ឋកថា សមន្តប្បាសាទិកា អដ្ឋកថា និងកង្ខាវិតរណីខែថា ៖*

អគាមកេ បន អរញ្ញេ សមន្តា សត្តព្ភន្តរា សត្តព្ភន្តរសីមា នាម ។ *ក៏ប្រាំពីរអព្ភន្តរៈដោយជុំវិញក្នុងព្រៃ ដែលមិនមែនជាស្រុក ឈ្មោះថា សត្តព្ភន្តរសីមា ។*

តត្ថ អគាមកំ នាម អរញ្ញំ វិញ្ឈាដវីអាទីសុ វា សមុទ្ទមជ្ឈេ វា មច្ឆពន្ធានំ អគមនបថេ ទីបកេសុ លព្ភតិ ។

*ឈ្មោះព្រៃមិនមែនស្រុក បានដល់ ព្រៃដូចព្រៃវិញ្ឈាដវី ជាដើម ឬក្នុងកោះទាំងឡាយកណ្តាលសមុទ្រដែលអ្នកនេសាទ ទាំងឡាយ មិនមានផ្លូវទៅដល់ ។*

*ព្រៃដែលព្រះភិក្ខុយកធ្វើជាអរញ្ញសីមាឬហៅថា អព្ភន្តរ-សីមា លុះត្រាព្រៃនោះ មិនមានមនុស្សទៅដល់ កោះនោះ មិនមានមនុស្សអាចសញ្ចរទៅមកបាន ។ ប្រសិនបើស្ថិតនៅក្នុងទី*

ដែលមនុស្សទៅបានទេ ព្រៃនោះក្តី កោះនោះក្តី នៅតែឈ្មោះថា គាមសីមា ។ ដូចនៅក្នុងវិនយាលង្ការដីកាពោលថា ៖

អសុកគាមស្ស ឥទំ ខេត្ត"ន្តិ គាមវោហារោ នត្ថិ, យត្ថ ច នេវ កសន្តិ ន វបន្តិ, តាទិសេ អរញ្ញេ ។ មច្ឆពន្ធានំ អគមនបថា និម្មនុស្សាវាសា សមុទ្ទន្តរទីបកាបិ ឯត្ថេវ សង្គយ្ហន្តិ ។ គាមវោហារដែលគេហៅថា “ទីនេះជាខេត្ត(ទឹកដី) របស់ស្រុកឈ្មោះនេះ” មិនមាន, ម្យ៉ាងទៀត មនុស្សទាំងឡាយ មិនភ្ជួរ ដាំដុះក្នុងទីណា ទីយ៉ាងនោះ ឈ្មោះថា ព្រៃ (ដែលអាចធ្វើជាអព្ភន្តរសីមាបាន) ។ សូម្បីក្នុងកោះក្នុងចន្លោះសមុទ្រ មិនមានមនុស្សនៅ ជាទីសញ្ចរនៃអ្នកនេសាទទៅមិនដល់ រមែងរាប់ថា ជាព្រៃនេះឯងដែរ ។

ខ្ញុំធ្លាប់អានសៀវភៅ“សីមាវិនិច្ឆ័យ”ខ្លះសរសេរថា ដែលហៅថា ព្រៃ វាស់ ១៩៦ ហត្ថពីស្រុក ។ គ្រាន់តែឃើញក៏នឹកក្នុងចិត្តថា ប្រាកដជាមិនសិក្សាយ៉ាងល្អិតក្នុងអដ្ឋកថា និងដីកា បានជាពោលភ្លាំងភ្លាត់យ៉ាងនេះ ។ ជួនអាចប្រឡំពាក្យថា ព្រៃ មិនមែនស្រុក ដែលមានក្នុងសំវិធានសិក្ខាបទ គឺក្នុងព្រៃកន្លះ

យោជន៍ រាប់ពីស្រុក ( អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ អាបត្តិ ចាចិត្តិយស្ស )។ អាចប្រឡំជាមួយទីង អារញ្ញកសេនាសនៈពោលថា សេនាសនៈប្រាំរយជួរធ្នូពីស្រុក ( អារញ្ញកំ នាម សេនាសនំ បញ្ចធនុសតិកំ បច្ឆិមំ ) ។ កន្លែងខ្លះអដ្ឋកថាពោលថា ចេញពីខាងក្រៅឥន្ទខីលទៅនៃស្រុកឡោមព័ទ្ធទីនោះទាំងអស់ជាព្រៃ (អគាមកេ អរញ្ញេតិ ឋត្វា និក្ខមិត្វា ពហិ ឥន្ទខីលា សព្វមេតំ អរញ្ញន្តិ ឋរំ វុត្តំ លក្ខណំ អរញ្ញំ )។ តែព្រៃព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យជាអព្ភន្តរសីមា មិនមែនមានលក្ខណៈយ៉ាងនេះទេ គឺមានលក្ខណៈដែលពោលមកខាងដើមនោះឯង ។ ដូចសមន្តប្បាសាទិកាបញ្ជាក់ហើយបញ្ជាក់ទៀតថា ៖

ទីឃកោ វា បត្ថតោ វា ហោតិ, សោ ចេ ទូរេ ហោតិ មច្ឆពន្ធានំ អគមនបថេ, អរញ្ញសីមាសង្ខ្យមេវ គច្ឆតិ ។ តេសំ គមនបរិយន្តស្ស ឱរតោ បន គាមសីមាសង្ខ្យំ គច្ឆតិ ។

ប្រសិនបើកោះឬភ្នំមានក្នុងសមុទ្រ, កោះឬភ្នំនោះ សែនឆ្ងាយ ដែលអ្នកនេសាទមិនអាចទៅដល់, ទីនោះរាប់ថា ជាអរញ្ញសីមា ។ តែបើអ្នកនេសាទអាចទៅដល់ទេ ទីនោះរាប់ថាគាមសីមា ។

តើប្រាំពីរអព្ភន្តរៈដោយជុំវិញរាប់ដូចម្តេច ?

នៅក្នុងអដ្ឋកថាខែថា ៖

សមន្តា សត្តព្ភន្តរានិ មជ្ឈេ ឋិតានំ សព្ពទិសាសុ សត្តព្ភន្តរា វិនិព្ពេធេន ចុទ្ទស ហោន្តិ ។

ត្រង់ពាក្យថា ៧ អព្ភន្តរៈដោយជុំវិញ សេចក្តីថា ៧ អព្ភន្តរៈក្នុងទិសទាំងឡាយទាំងពួងរបស់ភិក្ខុទាំងឡាយ ដែលឈរចំកណ្តាល (បើ)វាស់ដោយត្រង់មាន ១៤ អព្ភន្តរៈ ។

តត្ថ ឯកំ អព្ភន្តរំ អដ្ឋវីសតិហត្ថប្បមាណំ ហោតិ ។

បណ្តាអព្ភន្តរៈទាំងឡាយនោះ ១ អព្ភន្តរៈ មានប្រមាណ ២៨ ហត្ថ ។ ដូច្នេះ ២៨ x ២៨= ៧៨៤ ។

## ៣៤

## សូមមើលប្លង់




នេះជាប្លង់បញ្ជាក់ ក្នុងសេចក្តីដែលមានមកក្នុងអដ្ឋកថាទាំងឡាយ មានកង្ខាវិតរណីជាដើម ។ ដូច្នេះសង្ឃគង់ចំកណ្តាលនៃទិសទាំងបួន អព្ភន្តរៈក្នុងមួយទិសមាន ៧ បើគិតតាមត្រង់មួយខាង ៧ មួយខាង ៧ មាន ១៤អព្ភន្តរៈ អាចយក ១៤ x ២=២៨ អព្ភន្តរៈ ឬយក ៧ អព្ភន្តរគុណ ៤ ទិសក៏ឃើញដូចគ្នា (៧ x ៤=២៨) ។ អដ្ឋកថាបញ្ជាក់ថា ១ អព្ភន្តរៈស្មើ ២៨ ហត្ថ ។ ដូច្នេះយក ២៨ អព្ភន្តរៈគុណនឹង ២៨ ហត្ថ នឹងឃើញហត្ថទាំងអស់ហើយ ។ ដូច្នេះ ២៨ x ២៨=៧៨៤ ហត្ថ ។

សូមបញ្ជាក់ថា អព្ភន្តរៈនេះព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យវាស់ជីងផ្ទៃទំហំសីមា ដែលត្រូវគង់ធ្វើសង្ឃកម្ម ។ មិនមែនឲ្យ

*វាស់អព្ភន្តរៈនេះឲ្យដឹងចម្ងាយព្រៃទេ ដូចមានកេចិអាចារ្យពួកខ្លះពោលថា “ក្នុងអដ្ឋកថាថា ៧ អព្ភន្តរៈនោះមានប្រវែង ២៨ ហត្ថ x ៧=១៩៦ហត្ថ ពីស្រុក” ។ កេចិអាចារ្យលោកមានបំណងពោលថា ដែលហៅថា ព្រៃ វាស់ពីស្រុក ១៩៦ ហត្ថ ។ តែអព្ភន្តរៈនេះ មិនមែនអដ្ឋកថាចារ្យសំដៅយកការវាស់ឲ្យដឹងខ្នាតព្រៃ រាប់ចេញពីស្រុកនោះទេ ព្រះមានព្រះភាគទ្រង់មានបំណងឲ្យសាវ័កជ្រាបផ្ទៃទំហំសីមា ដែលសង្ឃត្រូវធ្វើសង្ឃកម្មក្នុងព្រៃនោះ ។*

អយញ្ហ សីមា បរិសាវសេន វឌ្ឍតិ, តស្មា សមន្តា បរិសាបរិយន្តតោ បដ្ឋាយ អព្ភន្តរបរិច្ឆេទោ កាតព្វោ ។ សចេ បន ទ្វេ សង្ឃា វិសុំ ឧបោសថំ ករោន្តិ, ទ្វិន្នំ សត្តព្ភន្តរានំ អន្តរេ អញ្ញមេកំ សត្តព្ភន្តរំ ឧបចារត្ថាយ ឋបេតព្វំ ។

*ក៏សីមានេះតែងរីកដោយអំណាចបរិស័ទ, ព្រោះហេតុនោះ ការកំណត់អព្ភន្តរៈចាប់ពីបរិស័ទខាងក្រោយគេបង្អស់ ហើយគួរធ្វើសង្ឃកម្មចុះ ។ ប្រសិនបើមានសង្ឃពីរពួកធ្វើឧបោសថផ្សេងគ្នា ត្រូវទុក ៧ អព្ភន្តរៈដទៃមួយក្នុងចន្លោះ ៧ អព្ភន្តរៈនៃសង្ឃទាំងពីរពួក ។*

# ឧទកុក្ខេបសីមា

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ហាមឃាត់មិនឲ្យយក ស្ទឹង សមុទ្រ និងជាតស្រះធ្វើជាពទ្ធសីមាថា សព្វា ភិក្ខវេ នទី អសីមា, សព្វោ សមុទ្ទោ អសីមោ, សព្វោ ជាតស្សរោ អសីមោ ម្នាលភិក្ខុទាំងឡាយ ស្ទឹងទាំងអស់មិនមែនជាសីមា, សមុទ្រទាំងអស់មិនមែនជាសីមា, ជាតស្រះទាំងអស់មិនមែនជាសីមា។ តែខាងក្រោយមកព្រះអង្គទ្រង់អនុញ្ញាតឲ្យយកជាអពទ្ធសីមាថា

នទិយា វា ភិក្ខវេ សមុទ្ទេ វា ជាតស្សរេ វា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា, អយំ តត្ថ សមាន–សំវាសា ឯកូបោសថា ។

ម្នាលភិក្ខុទាំងឡាយ ទីណាដែលបុគ្គលកំណត់ ដោយសាចទឹករបស់មជ្ឈិមបុរសដោយជុំវិញក្នុងស្ទឹងក្តី ក្នុងសមុទ្រក្តី ក្នុងជាតស្រះក្តី ទីនេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងទីមានស្ទឹងជាដើមនោះ ។

ឧទកុក្ខេបសីមានេះ កំណត់យកទីសាចទឹកឬខ្សាច់របស់បុរសមានកម្លាំងកណ្តាល ដូចក្នុងអដ្ឋកថាថា ៖

យំ ឋានំ ថាមមជ្ឈិមស្ស បុរិសស្ស សមន្តតោ ឧទកុក្ខេបេន បរិច្ឆិន្នំ, អយំ ឧទកុក្ខេបសីមា នាម ។

ទីសាចទឹកដោយជុំវិញរបស់បុរសមានកម្លាំងកណ្តាល ឯណា, ទីនេះឈ្មោះថា ឧទកុក្ខេបសីមា ។

តើស្ទឹង សមុទ្រ ជាតស្រះដូចម្តេច ដែលអាចយកធ្វើជាឧទកុក្ខេបសីមាបាននោះ ?

នៅក្នុងអដ្ឋកថាបញ្ជាក់ពីសមុទ្រថា ៖

សមុទ្ទោបិ ធាតកោយេវ ។ ឯសមុទ្រប្រាកដច្បាស់ហើយ (មិនមានលក្ខណៈប្រែប្រួលឡើយ) ។

តែអដ្ឋកថាបញ្ជាក់ពីស្ទឹងថា នទី នទីនិមិត្តេ វុត្ត-លក្ខណាវ ។ ស្ទឹងមានលក្ខណៈដូចពោលនៅក្នុងនទីនិមិត្តនោះឯង ។

នៅក្នុងលក្ខណៈនៃស្ទឹងអដ្ឋកថាពន្យល់ថា ៖

យស្មា ធម្មិកានំ រាជូនំ កាលេ អន្វឌ្ឍមាសំ អនុទសាហំ អនុបញ្ចាហន្តិ ឯវំ ទេវេ វស្សន្តេ វលាហកេសុ វិគតមត្តេសុ សោតំ បច្ឆិជ្ជតិ, អយំ នទីសង្ខ្យំ ន គច្ឆតិ ។ យស្មា បន ឦទិសេ សុវុដ្ឋិកាលេ វស្សានស្ស ចាតុមាសេ សោតំ ន បច្ឆិជ្ជតិ, យត្ថ តិត្ថេន វា អតិត្ថេន វា សិក្ខា-ករណីយេ អាគតលក្ខណេន តិមណ្ឌលំ បដិច្ឆាទេត្វា អន្តរវាសកំ អនុក្ខិបិត្វា ឧត្តរន្តិយា ភិក្ខុនិយា ឯកង្គុល-ទ្វង្គុលមត្តម្បិ អន្តរវាសកោ តេមិយតិ, អយំ នទី សីមំ ពន្ធន្តានំ និមិត្តំ ហោតិ ។ ភិក្ខុនិយា នទីបារគមនេបិ ឧបោសថាទិសង្ឃកម្មករណេបិ នទីបារសីមាសម្មន្នេបិ អយមេវ នទី ។

*ក្នុងកាលនៃស្តេចធម្មិករាជ ភ្លៀងធ្លាក់ចុះមកយ៉ាងនេះគឺ កន្លះខែភ្លៀងម្តង ១ ដប់ថ្ងៃភ្លៀងម្តង១ ប្រាំថ្ងៃភ្លៀងម្តង១ ដូច្នេះ*

ត្រឹមតែភ្លៀងរាំង ក្រសែទឹកក្នុងស្ទឹងឯណា ដាច់ទៅ, ស្ទឹងនេះមិនរាប់ថាជា នទី (ក្នុងឧទកុក្ខេបសីមា)នេះទេ ។ តែកាលភ្លៀងល្អប្រាកដយ៉ាងនេះ គឺកន្ទុះខែភ្លៀងម្តង ៗ ដប់ថ្ងៃភ្លៀងម្តងៗប្រាំថ្ងៃភ្លៀងម្តងៗ ក្រសែទឹកក្នុងស្ទឹងណាមិនដាច់ អស់បួនខែនៃវស្សានរដូវ, ភិក្ខុនីស្លៀកស្បង់បិទបាំងមណ្ឌលតាមលក្ខណៈមានមកក្នុងសេក្ខិយវត្ត ហើយចូងក្នុងស្ទឹងណាតាមកំពង់ក្តី មិនមែនកំពង់ក្តី ស្បង់ទទឹកត្រឹមមួយផ្ទាប់ឬពីរផ្ទាប់, ស្ទឹងនេះឯងទើបគួរដល់ការចងនិមិត្ត ។ ស្ទឹងនេះឯង ដែលព្រះមានព្រះភាគកាន់យក សម្បីភិក្ខុនីអ្នកទៅកាន់ត្រើយស្ទឹង សម្បីធ្វើសង្ឃកម្មមានឧបោសថជាដើម សម្បីការសេន្ទតនទីបារសីមា ។

ការសិក្សាក្នុងអដ្ឋកថាទាំងឡាយទៅឃើញថា ស្ទឹងដែលអាចយកធ្វើជាឧទកុក្ខេបសីមាបាន លុះត្រាត្រូវតាមនទីលក្ខណៈ បើមិនត្រូវតាមនទីលក្ខណៈទេ ស្ទឹងនោះនៅតែជាគាមសីមា ។ កាលធ្វើសង្ឃកម្មក្នុងស្ទឹងដែលមិនដល់លក្ខណៈសង្ឃកម្មឈ្មោះថាមិនត្រឹមត្រូវតាមព្រះវិន័យឡើយ ។

លក្ខណៈនៃស្ទឹងគឺក្នុសម័យព្រះរាជាធម្មិករាជ ទ្រង់គ្រប់គ្រងដែនមានភ្លៀងធ្លាក់យ៉ាងនេះគឺ ១៥ ថ្ងៃភ្លៀងម្តង ១៥ ថ្ងៃ

ក្រោយមកភ្លៀងធ្លាក់ម្តងទៀត ១៥ ថ្ងៃ ក្រោយមកភ្លៀងធ្លាក់ម្តងទៀត រហូតគ្រប់ ៤ ខែ ក្នុងវស្សានរដូវ ។ ១ ខែ ភ្លៀងធ្លាក់ ២ ដង ដូច្នេះ ៤ ខែ ភ្លៀងធ្លាក់ ៨ ដង ។ មិនមែនភ្លៀងធ្លាក់ ៥ ថ្ងៃភ្លៀងម្តង ៦ ថ្ងៃ ភ្លៀងម្តង ជូន ១៥ ថ្ងៃទើបមានភ្លៀងម្តងនោះទេ ។

បើមិនភ្លៀង ១៥ ថ្ងៃម្តងទេ គឺ ភ្លៀង១០ ថ្ងៃ ភ្លៀងធ្លាក់ម្តងៗរហូត ៤ ខែ ។ បើភ្លៀង ១០ ថ្ងៃម្តង ក្នុង ១ ខែ ភ្លៀង ៣ ដង ដូច្នេះ ៣ x ៤= ១២ ។ ក្នុងបួនខែ មានភ្លៀង ១២ ដង ។

បើមិនភ្លៀង ១០ ថ្ងៃម្តងទេ គឺ ភ្លៀង ៥ ថ្ងៃ ភ្លៀងធ្លាក់ម្តងៗរហូត ៤ ខែ ។ បើភ្លៀង ៥ ថ្ងៃម្តង ក្នុង ១ ខែ ភ្លៀង ៦ ដង ដូច្នេះ ៦ x ៤= ២៤ ។ ក្នុងបួនខែ មានភ្លៀង ២៤ ដង ។

កាលភ្លៀងធ្លាក់ត្រឹមត្រូវយ៉ាងនេះហើយ ក្នុងស្ទឹងណាអាចមានទឹកដក់នៅរហូតបួនខែបាន ឬកិត្តិទីស្មៀកស្បង់មានបរិមណ្ឌលត្រឹមត្រូវច្លងក្នុងទឹកស្ទឹងយ៉ាងនេះ ទឹកអាចធ្វើឲ្យទទឹកស្បង់កិត្តិទីនោះ ត្រឹមមួយធ្នាប់ក៏ដោយ ពីរធ្នាប់ក៏ដោយស្ទឹងយ៉ាងនេះ ទើបយកធ្វើជានទីលក្ខណៈបាន ។

តើហេតុអ្វីយើងហ៊ានប្រែពាក្យថា អន្វឌ្ឍមាសំ កន្លះខែ

មួងៗ នោះ ?

មានគម្ពីរអដ្ឋកថា ដីកាជាច្រើនឲ្យប្រែយ៉ាងនេះ សូម

សិក្សាទាំងអស់គ្នាដូចតទៅ ៖

អដ្ឋកថា សមន្តបាសាទិកា ត្រង់ឧភតោវិភង្គ ក្នុង

ឧភតោវិភង្គវគ្គខែថា ៖

អន្វឌ្ឍមាសន្តិ អឌ្ឍមាសេ អឌ្ឍមាសេ ។

បទ អន្វឌ្ឍមាសំ បានសេចក្តីថា ក្នុងកន្លះខែម្តង កន្លះ

ខែម្តង ។

នៅក្នុងបាចិត្យាទិយោជនាខែត្រង់សិក្ខាបទនេះថា ៖

អន្វឌ្ឍមាសន្តិ ឯត្ថ អនុសទ្ទោ វិច្ឆត្ថវាចកោ,"អឌ្ឍ-

មាសេ អឌ្ឍមាសេ"តិ ។

បទថា អន្វឌ្ឍមាសំ សេចក្តីថា អនុសព្ទ នេះ ចុះក្នុង-

វិច្ឆត្ថវាចកៈ, មានអត្ថថា "កន្លះខែម្តង កន្លះខែម្តង" ។

តាមនៅក្នុងគម្ពីរបទរូបសិទ្ធិលោកពន្យល់ពាក្យ វិច្ឆត្ថវា-ចកៈនេះ ចុះក្នុងអត្ថ ជួនៗ (ម្តងហើយ ម្តងទៀត) ។

កង្ខាវិតរណីអភិនវដីកា ឈ្មោះ វិនយត្ថមញ្ជូសាខែថា៖

អនុ អនុ អឌ្ឍមាសំ អន្វឌ្ឍមាសំ, អឌ្ឍមាសេ អឌ្ឍមាសេតិ អត្ថោ ។

កន្លះខែតាមលំដាប់ៗ ឈ្មោះថា អន្វឌ្ឍមាសំ, អធិប្បាយថា កន្លះខែម្តង កន្លះខែម្តង ។

វជិរពុទ្ធិដីកាខែត្រង់នេះថា ៖

អន្វឌ្ឍមាសន្តិ ឯត្ថ អនុពទ្ធោ អឌ្ឍមាសោ, អឌ្ឍមាសស្ស វា អនុ ។

បទថា អន្វឌ្ឍមាសំ នេះ មានសេចក្តីថា កន្លះខែមិនដាច់គ្នាតាមលំដាប់, ម្យ៉ាងទៀត តាមលំដាប់នៃកន្លះខែ ។

សីលក្ខន្ធវគ្គអភិនវដីកាត្រង់សាមញ្ញផលសុត្តវណ្ណនាថា:

អន្វឌ្ឍមាសន្តិ ឯត្ថ អនុសទ្ទោ ព្យាបនេ ។ វស្សានស្ស អឌ្ឍមាសំ អឌ្ឍមាសន្តិ អត្ថោ ។ ឯវំ អនុទសាហន្តិ ឯត្ថាបិ ។

*បទថា អន្វឌ្ឍមាសំ នេះ អនុសព្ទ ចុះក្នុងអត្ថ ព្យាបនៈ ។ អធិប្បាយថា កន្លះខែម្តង កន្លះខែម្តង នៃវស្សានរដូវ ។ សូម្បី ក្នុងបទថា អនុទសាហំ ក៏មានន័យដូចគ្នា ។*

*អង្គុត្តរនិកាយអភិនវដីកា ឈ្មោះ សារត្ថមញ្ជូសា ក្នុងអដ្ឋកនិបាតនិងសារត្ថទីបនីដីកាខែ ត្រង់សំដែងអាណាបាតិមោក្ខ របស់ភិក្ខុថា ៖*

"សុណាតុ មេ ភន្តេ"តិអាទិកំ អាណាបាតិមោក្ខំ, តំ សាវកា ឧទ្ទិសន្តិ, ន ពុទ្ធា, យំ អន្វឌ្ឍមាសំ ឧទ្ទិសីយតិ ។

*អាណាបាតិមោក្ខ មាន សុណាតុ មេ ភន្តេ ជាដើម, សាវករបស់ព្រះមានព្រះភាគតែម្យ៉ាង សំដែងនូវអាណាបាតិ-មោក្ខនោះ, មិនមែនព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងទេ, សាវកព្រះពុទ្ធតែងសំដែងរាល់កន្លះខែម្តងៗ ។*

ពិតយ៉ាងនោះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុធ្វើឧបោសថរៀងរាល់កន្លះខែម្តងៗ ដែលមានមកក្នុងវិនយបិដកមហាវគ្គ ភាគ ៦ ទំព័រ ៣៤៥ ។

ដូច្នេះ ពាក្យថា អន្វឌ្ឍមាសំ នេះ ត្រូវប្រែថា កន្លះខែម្តងកន្លះខែម្តងតាមលំដាប់ ។

តែស្រាប់តែប្លែកក្នុងចិត្តកើតឡើង ត្រង់សីមាវិនិច្ឆ័យនេះដែលបាចិត្យាទិយោជនាខែថា ៖

"អន្វឌ្ឍមាស"ន្តិអាទិនា ឯកបក្ខេ តិក្ខត្តុំ ឯកមាសេ ឆក្ខត្តុំ វស្សន្តភាវំ ទីបេតិ។

អដ្ឋកថាចារ្យរមែងសំដែងនូវភាវៈនៃភ្លៀងក្នុងមួយបក្ខ ៣ ដង ក្នុងមួយខែ ៦ ដង ដោយបទជាដើមថា អន្វឌ្ឍមាសំ នេះ ។

កាលត្រួតពិនិត្យទៅទើបឃើញថា លោកមានបំណងខែត្រង់ពាក្យថា អនុបញ្ញាហំ ទេ ។ អាចមានការភ្លាំងភ្លាត់ដោយការបោះតៗគ្នាមក មិនខាន ។ តាមសេចក្តីនេះ បើភ្លៀង ៥ ថ្ងៃម្តង

ក្នុងមួយបក្ខ ភ្លៀងមាន ៣ ដង, ក្នុងមួយខែ មានភ្លៀង ៦ ដង ។ កាលបើយ៉ាងនេះ បាលីនេះគួរមានរូបយ៉ាងនេះ ៖

“អនុបញ្ញាហ”ន្តិអាទិនា ឯកបក្ខេ តិក្ខត្តុំ ឯកមាសេ ឆក្ខត្តុំ វស្សន្តភាវំ ទីបេតិ ។

## សេចក្ដីអធិប្បាយ

ឧទកុក្ខេបសីមា មានទីកំណត់ជុំវិញដោយការសាចទឹកឬខ្សាច់របស់មជ្ឈិមបុរស មានកម្លាំងកណ្ដាល ។ ការសាចទឹកធ្លាក់ចុះទីកំណត់ត្រឹមណា ទីកំណត់ត្រឹមណោះ ជាមួយឧទកុក្ខេប ។ តែផ្ទៃសីមានេះ រមែងរីកទៅតាមបរិស័ទ ដែលគង់នៅក្នុងផ្ទៃឧទកុក្ខេបសីមា ហើយវាស់ផ្ទៃសីមាពីភិក្ខុដែលគង់នៅខាងក្រោយគេបង្អស់ ។ កាលភិក្ខុធ្វើសង្ឃកម្មក្នុងសីមានេះ ត្រូវបោះយុថ្កា ឬត្រូវចងក្បូន ទុកទៅសសរដែលនៅក្នុងស្ទឹងនោះ ហើយធ្វើសង្ឃកម្មចុះ ។ បើបើចងទូកទៅនឹងដង្កត់ឈើនៅមាត់ស្ទឹងឬយកខ្សែរចងនឹង

ដើមឈើនៅមាត់ច្រាំង សង្ឃកម្មខូច ព្រោះសីមាសង្ករៈនឹងគ្នា ជាមួយគាមសីមា ។ សង្ឃកម្មទៅជាបរិសវិបត្តិ ។

កាលភិក្ខុធ្វើសង្ឃកម្មដោយមិនបានបោះយុថ្កា ឬមិនបានចងនឹងបង្គោលក្នុងស្ទឹងនោះ សង្ឃកម្មអាចខូច ដោយសារទូករសាត់ទៅកន្លែងផ្សេងផុតពីមួយឧទកុក្ខេប ដែលជាផ្ទៃសីមារបស់ខ្លួនកំពុងធ្វើសង្ឃកម្ម ដូច្នេះញត្តិនៅក្នុងសីមាដទៃ អនុស្សាវនានៅក្នុងសីមាដទៃ ។

កាលបើមានស្ពាននៅក្នុងស្ទឹងនោះ សសរស្ពានមានតែក្នុងផ្ទៃស្ទឹងប៉ុណ្ណោះ មិនជាប់នឹងផ្ទៃដីច្រាំង ទាំងក្បាលស្ពានទាំងពីរខាងបះផុតនឹងមាត់ដីទាំងសងខាង ភិក្ខុអាចធ្វើសង្ឃកម្មលើស្ពាននោះបាន ។ តែបើសសរស្ពានចាក់ចុះទៅផ្ទៃដីច្រាំង ឬក្បាលស្ពានប៉ះមាត់ដី ភិក្ខុមិនគួរធ្វើសង្ឃកម្មលើស្ពាននោះ កាលធ្វើទៅ សង្ឃកម្មខូចដោយសារសីមាសង្ករៈគ្នា ជាមួយគាមសីមា ។

កាលបើមានសង្ឃពីរពួកធ្វើសង្ឃកម្មក្នុងស៊ីមតែមួយ ជាមួយគ្នា ត្រូវទុកសីមន្តរិកមួយឧទកុក្ខេប ដល់គ្នាទៅវិញទៅមក ។

## ជាតស្រះ

ឯត្ថ ច ជាតស្សរោ នាម យេន កេនចិ ខណិត្វា អកតោ សយំជាតសោព្ភោ[1] សមន្តតោ អាគតេន ឧទកេន បូរិតោ តិដ្ឋតិ។

រណ្ដៅកើតឡើងខ្លួនឯង មិនមានអ្នកធ្វើ មិនមានអ្នកណាមួយជីក មានទឹកហូរមកដោយជុំវិញពេញរណ្ដៅនោះ ឈ្មោះថា ជាតស្រះ ។

វិនយាលង្ការដីកាខែថា ៖

---

១ សោព្ភោតិ សំ ឧភោតិ បទវិភាគោ កាតព្វោ។ តត្ថ សំសទ្ទោ សមន្តត្ថវាចកោ, ឧភសទ្ទោ បូរណត្ថវាចកោ ។ តស្មា សមន្តតោ អាគតេន ឧទកេន ឧភតិ បូរតិ ឯត្ថាតិ សោព្ភោតិ វចនត្ថោ កាតព្វោ ។ បាចិត្យាទិយោជនា ។

យេន កេនចីតិ អន្តមសោ សូករាទិនា សត្តេន។

ត្រង់ពាក្យថា មិនមានអ្នកណាមួយជីក សេចក្ដីថា ដោយហោចទៅ សូម្បីសត្វតិរច្ឆានទាំងឡាយ មានជ្រូកជាដើម មិនជីក (ឈូស) ឡើយ ។

នៅក្នុងវិនយសង្គហដ្ឋកថា ឈ្មោះបាលិមុត្តកវិនិច្ឆយៈ ខែថា៖

យោ បន យេន កេនចិ ខណិត្វា អកតោ សយំជាតោ សោព្ភោ សមន្តតោ អាគតេន ឧទកេន បូរិតោ តិដ្ឋតិ, យត្ថ នទិយំ វុត្តប្បការេ វស្សកាលេ ឧទកំ សន្តិដ្ឋតិ, អយំ ជាតស្សរោ នាម។

ចំណែករណ្ដៅណា កើតឡើងដោយខ្លួនឯង មិនមានអ្នកធ្វើ មិនមានអ្នកជីក មានទឹកហូរមកដោយជុំវិញដក់នៅ, ទឹកដក់នៅក្នុងកាលភ្លៀងមានប្រការដូចពោលហើយក្នុងស្ទឹងឯណា, រណ្ដៅទឹកនេះ ឈ្មោះថា ជាតស្រះ ។

កាលបើស្រះទឹក បឹង រណ្ដៅមានលក្ខណៈដូចពោល មកក្នុងអដ្ឋកថា ដីកាទាំងឡាយនេះហើយ ទីនោះសង្ឃអាច ធ្វើសង្ឃកម្ម ជាឧទកុក្ខេបសីមាបានដូចធ្វើក្នុងស្ទឹងដែរ ។ របៀបធ្វើសង្ឃកម្មក្នុងជាតស្រះ មានប្រការដូចពោលទុក ក្នុងស្ទឹងនោះឯង ។

ចប់អពទ្ធសីមា

# ពទ្ធសីមា

កាលបើសិក្សាលំអិតក្នុងគាមសីមា និងវិសុំគាមសីមាយ៉ាងច្បាស់ហើយ មានបំណងចងនូវពទ្ធសីមាក្នុងគាមសីមា ឬវិសុំគាមសីមា គប្បីធ្វើការចងចុះ ។

កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខខៃថា ៖

តត្ថ ឯកាទស វិបត្តិសីមាយោ អតិក្កមិត្វា តិវិធ-សម្បត្តិយុត្តា និមិត្តេន និមិត្តំ សម្ពន្ធិត្វា សម្មតា សីមា ពទ្ធសីមា នាម ។

បណ្ដាសីមាទាំងឡាយពីរនោះ សីមាណាកន្លងនូវវិបត្តិ ១១ យ៉ាង ប្រកបព្រមដោយសម្បត្តិ ៣ យ៉ាង ចងនូវនិមិត្តដោយនិមិត្ត ហើយសន្មត សីមានោះ ឈ្មោះថា ពទ្ធសីមា ។

## សីមាវិបត្តិ ១១ យ៉ាង

១.អតិខុទ្ទកា សីមាតូចពេក ។ បានសេចក្ដីថា ភិក្ខុ ២១ រូបមិនអាចអង្គុយចុះក្នុងផ្ទៃសីមាណា សីមានោះ ឈ្មោះ សីមាតូចពេក ។

២.អតិមហតី *សីមាធំពេក ។ បានសេចក្តីថា កិក្ខុសន្មត សីមាកន្លងហួស ៣ យោជន៍ សូម្បីត្រឹមមួយសរសៃសក់ ។*

៣.ខណ្ឌនិមិត្តា *សីមាមាននិមិត្តដាច់ ។ បានសេចក្តីថា សីមាមាននិមិត្តមិនជាប់គ្នា ដូចវិនយធរកំណត់និមិត្តក្នុងទិស ខាងកើត បន្ទាប់មកទិសខាងត្បូង,ខាងលិច,ខាងជើង ហើយឈប់ នៅក្នុងទិសខាងជើងនោះ មិនកំណត់ទិសខាងកើតម្តងទៀត យ៉ាង នេះ ឈ្មោះថា សីមាមាននិមិត្តដាច់ ។ ឬក៏វិនយធរយកវត្ថុណា មួយដែលមិនគួរដល់និមិត្តមកធ្វើជា និមិត្តក្នុងចន្លោះ នេះក៏ ឈ្មោះថា សីមាមាននិមិត្តដាច់ដែរ ។*

៤.ឆាយានិមិត្តា *សីមាយកស្រមោលជានិមិត្ត ។ បាន សេចក្តីថា វិនយធរធ្វើស្រមោលណាមួយ មានស្រមោលភ្នំ ជាដើម ឲ្យជានិមិត្ត ហើយសន្មត សីមានេះ ឈ្មោះថា សីមា យកស្រមោលជានិមិត្ត ។*

៥.អនិមិត្តា *សីមាមិនមាននិមិត្ត ។ បានសេចក្តីថា វិនយធរមិនបានកំណត់នូវនិមិត្តទាំងអស់ ហើយសន្មត យ៉ាង នេះ ឈ្មោះថា សីមាមិនមាននិមិត្ត ។*

៦. ពហិសីមេ ឋិតា សម្មុតា *សីមាកំណត់និមិត្តខាងក្រៅសីមា ។ បានសេចក្តីថា វិនយធរឈរខាងក្រៅនិមិត្តហើយកំណត់និមិត្ត ។*

៧.នទិយា សម្មុតា *សីមាដែលភិក្ខុសន្មតក្នុងស្ទឹង ។*

៨.សមុទ្ទេ សម្មុតា *សីមាដែលភិក្ខុសន្មតក្នុងសមុទ្រ។*

៩.ជាតស្សរេ សម្មុតា*សីមាដែលភិក្ខុសន្មតក្នុងជាតស្រះ ។*

១០.សីមាយ សីមំ សម្ភិន្ទន្តេន សម្មុតា *សន្មតសីមាដោយទំលាយនូវសីមា ។*

១១.សីមាយ សីមំ អជ្ឈោត្ថរន្តេន សម្មុតា *សន្មតសីមាដោយគ្របសង្កត់នូវសីមា ។*

## សម្បត្តិ ៣ យ៉ាង

*អដ្ឋកថា កង្ខាវិតរណីថែថា ៖*

តិសម្បត្តិសំយុត្តាតិ និមិត្តសម្បត្តិ, បរិសសម្បត្តិ, កម្មវាចាសម្បត្តីតិ ឥមាហិ តីហិ សម្បត្តីហិ សមន្នាគតា។

សីមាប្រកបព្រមដោយសម្បត្តិទាំងឡាយ ៣ នេះគឺ និមិត្តសម្បត្តិ១ បរិសាសម្បត្តិ ១ កម្មវាចាសម្បត្តិ ១ ។

## និមិត្តសម្បត្តិ

| | |
|---|---|
| ១.បព្វតនិមិត្ត | យកភ្នំជានិមិត្ត ។ |
| ២.បាសាណនិមិត្ត | យកថ្មជានិមិត្ត ។ |
| ៣.វននិមិត្ត | យកព្រៃជានិមិត្ត ។ |
| ៤.រុក្ខនិមិត្ត | យកដើមឈើជានិមិត្ត ។ |
| ៥.មគ្គនិមិត្ត | យកផ្លូវជានិមិត្ត ។ |
| ៦.វម្មិកនិមិត្ត | យកដំបូកជានិមិត្ត ។ |
| ៧. នទិនិមិត្ត | យកស្ទឹងជានិមិត្ត ។ |
| ៨.ឧទកនិមិត្ត | យកទឹកជានិមិត្ត ។ |

# អធិប្បាយបាសាណនិមិត្ត

នៅក្នុងសៀវភៅសីមាវិនិច្ឆ័យផ្សេងៗ មានការអធិប្បាយនូវនិមិត្តទាំងអស់នេះហើយ ។ តែក្នុងទីនេះ ខ្ញុំសូមលើកយកបាសាណនិមិត្ត (យកថ្មជានិមិត្ត) មកអធិប្បាយដូចតទៅ ៖

នៅក្នុងអដ្ឋកថាបញ្ជាក់ថា ថ្មយ៉ាងណាមួយក៏គួរ, សូម្បីដុំដែកក៏រាប់ថា ជាថ្ម អាចយកធ្វើជានិមិត្តបាន ។ ទំហំថ្មយ៉ាងធំប៉ុនគោឡើងនិងក្របីឡើង ។ បើថ្មធំប៉ុនដំរី មិនអាចយកធ្វើជានិមិត្តបានឡើយ ព្រោះថ្មប៉ុនដំរីនោះ ចាត់ទុកថា ជាភ្នំទៅវិញ ។ ទំហំថ្មយ៉ាងតូចបំផុតដែលគួរយកធ្វើជានិមិត្តបាននោះ ក្នុងអដ្ឋកថាបញ្ជាក់ថា ហេដ្ឋិមបរិច្ឆេទេន ទ្វត្តឹសបលគុឡបិណ្ឌបរិមាណោ វដ្ដតិ ។ ថ្មប្រមាណដុំស្ករអំពៅ ៣២ បលៈ ដោយកំណត់យ៉ាងតូចបំផុត គួរធ្វើនិមិត្តបាន ។

នៅក្នុងវិនយត្ថមញ្ជូសា កង្ខាវិតរណីអភិនវដីកាខែថា ៖

ទ្វត្តឹសបលគុឡបិណ្ឌបរិមាណោតិ ថូលតាយ, ន តុលគណនាយ ។ ត្រង់ពាក្យថា ថ្មប្រមាណដុំស្ករអំពៅ ៣២

*បលៈ នេះ យកប្រមាណដោយទំហំ (មាឌ) មិនមែនដោយការច្រើនទេ ។*

*នៅក្នុងវិនយាលង្ការដីកាខែថា ៖*

ទុត្តិំសបលគុឡបិណ្ឌប្បមាណតា សណ្ឋានតោ កហេតព្វា, ន តុលគណនាវសេន, ភារតោ បល-បរិមាណញ្ច មគធតុលាយ គហេតព្វំ, សា ច លោកិយ-តុលាយ ទ្វិគុណាតិ វទន្តិ ។

*អាចារ្យទាំងឡាយពោលថា ដុំប្រមាណដុំស្ករអំពៅ ៣២ បលៈ បណ្ឌិតគប្បីកាន់យកដោយទ្រង់ទ្រាយសណ្ឋាន, មិនមែនដោយការច្រើនជញ្ជីងទេ, ចំណែកប្រមាណបលៈដោយទម្ងន់ គប្បីកាន់យកដោយជញ្ជីងមគធៈ ក៏ជញ្ជីងមគធៈនោះ គុណទ្វីងពីរដោយជញ្ជីងលោកិយ ។*

## បរិសសម្បត្តិ

បរិសសម្បត្តិយុត្តា នាម សព្វន្តិមេន បរិច្ឆេទេន ចតូហិ ភិក្ខូហិ សន្និបតិត្វា យាវតិកា តស្មឹ គាមក្ខេត្តេ

ពទ្ធសីមំ វា នទីសមុទ្ទជាតស្សរេ វា អនោក្កមិត្វា ឋិតា ភិក្ខូ, តេ សព្វេ ហត្ថបាសេ វា កត្វា ឆន្ទំ វា អាហរិត្វា សម្មតា។

*ភិក្ខុទាំងឡាយស្ថិតនៅក្នុងគាមក្ខេត្តនោះ មានទីកំណត់ត្រឹមណា មិនចុះទៅកាន់ពទ្ធសីមាឬស្ទឹង សមុទ្រ ជាតស្រះ ដោយកំណត់យ៉ាងតិចបំផុតភិក្ខុ ៤ អង្គប្រជុំគ្នា, ត្រូវធ្វើភិក្ខុទាំងអស់នោះមកកាន់ហត្ថបាសឬនាំឆន្ទៈមក ហើយសន្មតចុះ ។*

## កម្មវាចាសម្បត្តិ

*ការដល់ព្រមដោយកម្មវាចា គឺសង្ឃគប្បីសូត្រនូវកម្មវាចាដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ មានមកក្នុងវិនយបិដកមហាវគ្គ ទឹងមានក្នុងទំព័រខាងមុខ ។ ការសូត្រនោះទៀតសោតត្រូវសូត្រជាភាសាមគធៈ មិនមែនសូត្រជាភាសាខ្មែរនោះឡើយ ។*

# សីមាពន្ធនវិធី

ព្រះភិក្ខុដែលជាអ្នកសន្មតនូវមហាសីមា ឬខណ្ឌសីមាត្រូវតម្កល់នូវនិមិត្តទាំងឡាយយ៉ាងតិចបំផុត ៣ ហើយសន្មតសីមាតាមសមគួរចុះ ។

តើមហាសីមានោះយ៉ាងណា ?

មហាសីមាគឺជាអវិប្បវាសសីមា សម្រាប់ព្រះភិក្ខុនៅប្រាសចាកត្រៃចីវរ ដូចមានក្នុងវិនយបិដក មហាវគ្គ ភាគ ៦ ទំព័រ ៣៥៦ ព្រះមានព្រះភាគទ្រង់អនុញ្ញាតថា យា សា ភិក្ខវេ សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នតុ ។

ម្នាលភិក្ខុទាំងឡាយ សីមាណាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដែលសង្ឃសន្មតហើយ ចូរសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បវាសសីមាចុះ ។

នៅក្នុងសមានសំវាសកសីមា ដែលព្រះភិក្ខុសង្ឃសន្មតរួចហើយ ត្រូវសន្មតតិចីវរាវិប្បវាសសីមាបន្ថែមពីលើទៀត ។ សីមា

នោះមានឈ្មោះថា អវិប្បវាសសីមា ឬហៅថា មហាសីមា ។

សារត្ថទីបនីដីកាពន្យល់ពាក្យសីមានេះថា ៖

អវិប្បវាសសីមា ឆ សម្ពហុលត្តា មហាសីមំ សន្ធាយ វុត្តំ ។

ត្រង់ពាក្យថា មិនគប្បីដកអវិប្បវាសសីមា បានសេចក្តីថា អដ្ឋកថាចារ្យពោលសំដៅយកមហាសីមា ។

វិមតិវិនោទនីដីកានិងវិនយាលង្ការដីកាខែថា ៖

អវិប្បវាសសីមាតិ មហាសីមំ សន្ធាយ វុត្តំ ។

ពាក្យថា អវិប្បវាសសីមា នេះ គឺអដ្ឋកថាចារ្យពោលសំដៅយកមហាសីមា ។

សរុបមក អវិប្បវាសសីមា នេះ ដែលក្នុងអដ្ឋកថាទាំងឡាយ តែងហៅឈ្មោះថា មហាសីមា ។

កាលភិក្ខុទាំងឡាយប្រាថ្នានឹងចងនូវសីមាពីរជាន់គឺមហា–សីមា និង ខណ្ឌសីមា នោះ ត្រូវកំណត់និមិត្តខណ្ឌសីមាជាមុន

ហើយគប្បីសូធ្យកម្មវាចាសន្មតខណ្ឌសីមាចុះ ។ បន្ទាប់មកគប្បីធ្វើនិមិត្តសីមន្តរិកទុកចន្លោះនៃសីមាទាំងពីរចំនួន ១ ហត្ថ ឬ ១ ចំអាម ឬយ៉ាងតូចបំផុត ៤ ធ្នាប់ ហើយគប្បីកំណត់និមិត្តសីមន្តរិកដូចនិមិត្តនៃខណ្ឌសីមាដែរ ។ កាលកំណត់និមិត្តសីមន្តរិករួចហើយគប្បីមកកំណត់និមិត្តមហាសីមាដូចគ្នា ហើយសូធ្យកម្មវាចាសន្មតសមានសំវាសកសីមាជាមុនហើយ សូធ្យកម្មវាចាសន្មតតិចីវរា-វិប្បវាសសីមាជាខាងក្រោយ ។ម្យ៉ាងទៀត អដ្ឋកថាបញ្ជាក់ថាអាចកំណត់និមិត្តទាំង ៣ ឲ្យរួចស្រេចជាមុនសិនក៏បាន ហើយមានបំណងចងសីមាណាមុនក៏បាន ។ តែគួរចងពីខណ្ឌសីមាមកមុនល្អជាង ។ (សចេ បន ខណ្ឌសីមាយ និមិត្តានិ កិត្តេត្វា តតោ សីមន្តរិកាយ និមិត្តានិ កិត្តេត្វា មហាសីមាយ និមិត្តានិ កិត្តេន្តិ, ឯវំ តីសុ ឋានេសុ និមិត្តានិ កិត្តេត្វា យំ សីមំ ឥច្ឆន្តិ, តំ បឋមំ ពន្ធិតុំ វដ្ដតិ ។ ឯវំ សន្តេបិ យថាវុត្តនយេន ខណ្ឌសីមតោវ បដ្ឋាយ ពន្ធិតព្វា ។)

កាលមានបំណងចងខណ្ឌសីមា ត្រូវស្ថិតនៅក្នុងខណ្ឌសីមានោះ សូធ្យកម្មវាចាសន្មតខណ្ឌសីមាចុះ ។ កាលមានបំណងចង

មហាសីមា ត្រូវស្ថិតនៅក្នុងមហាសីមានោះ សូធ្យកម្មវាចាសន្មតមហាសីមាចុះ ។ កាលស្ថិតនៅក្នុងខណ្ឌសីមា មិនត្រូវចងមហាសីមាទេ ។ កាលស្ថិតនៅក្នុងមហាសីមា មិនត្រូវចងខណ្ឌសីមាទេ (ន ខណ្ឌសីមាយ ឋិតេហិ មហាសីមា ពន្ធិតព្វា, ន មហាសីមាយ ឋិតេហិ ខណ្ឌសីមា, ខណ្ឌសីមាយមេវ បន ឋត្វា ខណ្ឌសីមា ពន្ធិតព្វា, មហាសីមាយមេវ ឋត្វា មហាសីមា ។)

សូមមើលប្លង់សីមាខាងក្រោម ៖



នៅក្នុងអដ្ឋកថាបញ្ជាក់ថែមទៀតថា ៖

ឯវំ ពទ្ធាសុ បន សីមាសុ ខណ្ឌសីមាយ ឋិតា ភិក្ខូ មហាសីមាយ កម្មំ ករោន្តានំ ន កោបេន្តិ, មហាសីមាយ វា ឋិតា ខណ្ឌសីមាយ កម្មំ ករោន្តានំ សីមន្តរិកាយ បន ឋិតា ឧភិន្នម្បិ ន កោបេន្តិ ។ គាមក្ខេត្តេ ឋត្វា កម្មំ ករោន្តានំ បន សីមន្តរិកាយ ឋិតា កោបេន្តិ ។ សីមន្តរិកា ហិ គាមក្ខេត្តំ ភជតិ ។

កាលបើសីមាដែលសង្ឃចងយ៉ាងនេះហើយ ភិក្ខុទាំងឡាយ ដែលស្ថិតនៅក្នុងខណ្ឌសីមា មិនធ្វើឲ្យខូចកម្មដល់ភិក្ខុដែលស្ថិតនៅក្នុងមហាសីមា, ភិក្ខុទាំងឡាយ ដែលស្ថិតនៅក្នុងមហាសីមា មិនធ្វើឲ្យខូចកម្មដល់ភិក្ខុដែលស្ថិតនៅក្នុងខណ្ឌសីមា, ភិក្ខុដែលនៅក្នុងសីមន្តរិក មិនធ្វើឲ្យខូចកម្មដល់ភិក្ខុដែលស្ថិតនៅក្នុងសីមាទាំងពីរគឺខណ្ឌសីមា និងមហាសីមា ។ តែភិក្ខុដែលស្ថិតនៅក្នុងសីមន្តរិក ធ្វើឲ្យខូចកម្មដល់ភិក្ខុ ដែលស្ថិតនៅក្នុងគាមក្ខេត្តគឺគាមសីមា ។ ព្រោះសីមន្តរិក រមែងរាប់ថា ជាគាមក្ខេត្តដដែល ។

# ខណ្ឌសីមា

*បើមានបំណងចងខណ្ឌសីមាតែម្យ៉ាងទេ ព្រះភិក្ខុសង្ឃគ្រាន់តែកំណត់និមិត្តជុំវិញឲ្យត្រឹមត្រូវតាមព្រះវិន័យរួចជាស្រេច ។ គប្បីធ្វើការដកសីមានិងចងសីមាចុះ ។ ការធ្វើខណ្ឌសីមាត្រូវឲ្យមានទំហំល្មមអាចភិក្ខុ ២១ អង្គគង់ចុះជារង្វង់មូលបាន ។ បើតូចជាងនោះ មិនគួរឡើយ សីមានោះ ឈ្មោះថា មានវិបត្តិ ។ ដូចអដ្ឋកថាបញ្ជាក់ថា ៖*

សា ហេដ្ឋិមបរិច្ឆេទេន សចេ ឯកវីសតិ ភិក្ខូ គណ្ហាតិ, វដ្ដតិ ។ តតោ ឱរំ ន វដ្ដតិ, បរំ ភិក្ខុសហស្សំ គណ្ហន្តីបិ វដ្ដតិ ។

*ខណ្ឌសីមានោះ ដោយកំណត់យ៉ាងតូចបំផុតល្មមភិក្ខុ ២១ អង្គគង់ចុះបាន, ទើបគួរ ។ បើតូចជាងនោះ មិនគួរឡើយ, តែបើល្មមសូម្បីដល់ទៅ ១០០០ អង្គ ក៏គួរដែរ ។*

*នៅក្នុងគម្ពីរសមន្តប្បាសាទិកាយោជនាខែថា ៖*

យត្ថ ឯកវីសតិ ភិក្ខូ និសីទិតុំ ន សក្កោន្តិ យស្សំ សីមាយំ ហេដ្ឋិមបរិច្ឆេទេន កម្មារហេន សទ្ធិំ ឯកវីសតិ បរិមណ្ឌលាការេន និសីទិតុំ ន សក្កោន្តិ ។

*ត្រង់ពាក្យអដ្ឋកថាចារ្យថា ភិក្ខុ ២១ រូបមិនអាចអង្គុយបាន ក្នុងសីមាណា (សីមានោះ ហៅថា សីមាតូចពេក) សេចក្តីថា ដោយកំណត់យ៉ាងតូចបំផុតភិក្ខុ ២១ រូប ព្រមទាំងភិក្ខុគួរដល់អព្ភានកម្ម មិនអាចអង្គុយបាន ដោយទ្រង់ទ្រាយជារង្វង់មូល ក្នុងសីមាណា ( សីមានោះ ហៅថា សីមាតូចពេក) ។*

*បើទីចង្វល់សីមាល្មមភិក្ខុ ២១ អង្គុគង់ជារង្វង់មូលបាន ហើយ ព្រះភិក្ខុជាមហាថេរ អ្នកឈ្លាស ប្រតិពល អង់អាចក្នុងសីមាពន្ធនវិធី គប្បីកំណត់និមិត្តដូច្នេះ ៖*

*ទិសបូព៌:* បុរត្ថិមាយ ទិសាយ កឹ និមិត្តំ *អ្វីជានិមិត្តក្នុងទិសខាងកើត ?*

*អ្នកណាមួយឆ្លើយថា:* បាសាណោ ភន្តេ *ថ្មលោកម្ចាស់ ។*

*វិនយធរគប្បីកំណត់ថា* ឯសោ បាសាណោ និមិត្តំ *ថ្មនុ៎ះជានិមិត្ត ។*

ទិសអគ្នេយ៍៖ បុរត្ថិមាយ អនុទិសាយ កឹ និមិត្តំ អ្វីជា និមិត្តក្នុងទិសអគ្នេយ៍ ?

អ្នកណាមួយឆ្លើយថា៖ ចាសាណោ ភន្តេ ជូលោកម្ចាស់ ។ វិនយធរគប្បីកំណត់ថា ឃសោ ចាសាណោ និមិត្តំ ជូនុះជានិមិត្ត ។

ទិសទក្សិណៈ ទក្ខិណាយ ទិសាយ កឹ និមិត្តំ អ្វីជា និមិត្តក្នុងទិសខាងត្បូង ?

អ្នកណាមួយឆ្លើយថា៖ ចាសាណោ ភន្តេ ជូលោកម្ចាស់ ។ វិនយធរគប្បីកំណត់ថា ឃសោ ចាសាណោ និមិត្តំ ជូនុះជានិមិត្ត ។

ទិសនិរតី៖ ទក្ខិណាយ អនុទិសាយ កឹ និមិត្តំ អ្វីជា និមិត្តក្នុងទិសនិរតី ?

អ្នកណាមួយឆ្លើយថា៖ ចាសាណោ ភន្តេ ជូលោកម្ចាស់ ។ វិនយធរគប្បីកំណត់ថា ឃសោ ចាសាណោ និមិត្តំ ជូនុះជានិមិត្ត ។

ទិសបស្ចិម៖ បច្ឆិមាយ ទិសាយ កឹ និមិត្តំ អ្វីជា និមិត្តក្នុងទិសខាងលិច ?

អ្នកណាមួយឆ្លើយថា៖ បាសាណោ ភន្តេ ថ្មលោកម្ចាស់ ។

វិនយធរគប្បីកំណត់ថា ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត ។

ទិសពាយព្យ៖ បច្ឆិមាយ អនុទិសាយ កិំ និមិត្តំ អ្វីជានិមិត្តក្នុងទិសពាយព្យ ?

អ្នកណាមួយឆ្លើយថា៖ បាសាណោ ភន្តេ ថ្មលោកម្ចាស់ ។

វិនយធរគប្បីកំណត់ថា ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត ។

ទិសឧត្តរ៖ ឧត្តរាយ ទិសាយ កិំ និមិត្តំ អ្វីជានិមិត្តក្នុងទិសខាងជើង ?

អ្នកណាមួយឆ្លើយថា៖ បាសាណោ ភន្តេ ថ្មលោកម្ចាស់ ។

វិនយធរគប្បីកំណត់ថា ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត ។

ទិសឦសាន៖ ឧត្តរាយ អនុទិសាយ កិំ និមិត្តំ អ្វីជានិមិត្តក្នុងទិសឦសាន ?

អ្នកណាមួយឆ្លើយថា៖ បាសាណោ ភន្តេ ថ្មលោកម្ចាស់ ។

វិនយធរគប្បីកំណត់ថា ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត ។

គប្បីកំណត់និមិត្តទិសខាងកើតម្តងទៀត ដើម្បីឲ្យនិមិត្តតគ្នា កុំឲ្យនិមិត្តដាច់ (ខណ្ឌនិមិត្តា) ។

ទិសបូព៌ៈ បុរត្ថិមាយ ទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសខាងកើត ?

អ្នកណាមួយឆ្លើយថា: បាសាណោ ភន្តេ ថ្មលោកម្ចាស់ ។ វិនយធរគប្បីកំណត់ថា ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត ។

កាលបើកំណត់និមិត្តយ៉ាងនេះហើយ គប្បីចងសីមាចុះ ។ ការកំណត់និមិត្តមហាសីមាក្តី ខណ្ឌសីមាក្តី សីមន្តរិកក្តី មានការកំណត់ដូចគ្នា ដូចពោលមកយ៉ាងនេះឯង ។

វត្ថុដែលអាចយកមកធ្វើជានិមិត្តបានមាន ៨ ដូចពោលខាងដើម ។ បើវិនយធរពេញចិត្តយកនិមិត្តមួយណាមកកំណត់ក៏បាន លាយនិមិត្តគ្នាក៏បាន ។ តែត្រូវកំណត់និមិត្តចាប់ពីបីឡើងទៅ ទើបគួរដល់ការចងសីមាបាន ។ បើកំណត់ត្រឹមតែនិមិត្តមួយ ឬនិមិត្តពីរមិនគួរសោះឡើយ ។ បើកំណត់និមិត្តមានទ្រង់ទ្រាយយ៉ាងណា ផ្ទៃសីមាក៏មានរូបរាងយ៉ាងនោះដូចគ្នា ។

# ពិធីដកសីមា

សីមាដែលជាពទ្ធសីមា កាលបើសង្ឃត្រូវដកត្រូវប្រកប ដោយហេតុពីរ ដូចអដ្ឋកថា សមន្តប្បាសាទិកាខែថា ៖

សីមំ ឆាម ទ្វីហិ ការណេហិ សមូហានន្តិ បកតិយា ខុទ្ទកំ បុន អាវាសវឌ្ឍនត្ថាយ មហតី វា កាតុំ; បកតិយា មហតី បុន អញ្ញេសំ វិហារោកាសទានត្ថាយ ខុទ្ទកំ វា កាតុំ ។

ភិក្ខុដកសីមា ដើម្បីធ្វើសីមាតូចតាមប្រក្រតីឲ្យធំជាងមុន ប្រយោជន៍ដល់ការពង្រីកអាវាស ១ ធ្វើការដកនូវសីមាធំតាមប្រក្រតីឲ្យតូចជាងមុន ដើម្បីទុកឱកាសដល់វត្ថុដទៃដែលត្រូវចង សីមា ១ ។

កាលបើមានបំណងយ៉ាងនេះ គួរដកចុះ ។ តែការដកទៀត សោត ត្រូវពិចារណាឲ្យបានល្អិតល្អន់ថា គួរដកយ៉ាងណា ។ នៅ ក្នុងព្រះពុទ្ធដីកានិងអដ្ឋកថាបញ្ជាក់ថា ត្រូវដកអវិប្បវាសសីមាជាមុន បន្ទាប់មកគប្បីដកសមានសំវាសកសីមាជាខាងក្រោយ ។ តែកាល

ដឹងយ៉ាងនេះហើយ ត្រូវជ្រាបពីផ្ទៃកំណត់សីមា (សីមាបរិច្ឆេទ) ឲ្យបានច្បាស់ថា ទីកំណត់សីមាមានត្រឹមណា ។ កាលដឹងច្បាស់ហើយ អាចដកបាន ។ ដូចអដ្ឋកថាបញ្ជាក់ថា សចេ ខណ្ឌ-សីមញ្ច អវិប្បវាសសីមញ្ច ជានន្តិ, សមូហនិតុញ្ចេវ ពន្ធិតុញ្ច សក្ខិស្សន្តិ ។ ខណ្ឌសីមំ បន ជានន្តា អវិប្បវាសំ អជានន្តាបិ សមូហនិតុញ្ចេវ ពន្ធិតុញ្ច សក្ខិស្សន្តិ ។

ប្រសិនបើភិក្ខុទាំងឡាយ ដឹងនូវខណ្ឌសីមាផង អវិប្ប-វាសសីមាផង, អាចដើម្បីដកផង និងចងផងមែនពិត ។ តែកាលដឹងខណ្ឌសីមាច្បាស់លាស់ សូម្បីមិនដឹងអវិប្បវាសសីមាក៏អាចដកបានផង ចងបានផងឥតខ្ចោះ ។

តាមន័យក្នុងអដ្ឋកថាបានបញ្ជាក់ហើយ កាលបើដឹងទីកំណត់ខណ្ឌសីមា ត្រូវសូធ្យដកតែម្តងទៅ មិនចាំបាច់ធ្វើកិច្ចផ្សេងៗ នាំឲ្យរំខានកិច្ចការសង្ឃទេ ដូចនាំគ្នា "ធ្វើការបញ្ជាន់តារាង"អីនេះ មិនចាំបាច់ធ្វើទេ ឲ្យតែសង្ឃបានដឹងច្បាស់ថា ទីកំណត់សីមា មានត្រឹមណាពិតប្រាកដ គ្រាន់តែនាំភិក្ខុមកកាន់ហត្ថបាសហើយសូធ្យដកជាការស្រេច ។

ចុះការបញ្ចូនតាពង ដើម្បីប្រយោជន៍អ្វី ?

ការបញ្ចូនតាពងសម្រាប់ភិក្ខុសង្ឃ ដែលលោកមិនដឹងទីកំណត់សីមាច្បាស់លាស់ ដូច្នេះ ក៏នាំបង្កើតបញ្ចូនតាពងនេះឯងឡើង ។ ការបញ្ចូនតាពងនេះ មុនដំបូងកើតក្នុងប្រទេសស្រីលង្កាទេ គឺមានសំដែងនៅក្នុងគម្ពីរវិមតិវិនោទនីដីកានូវរបៀបនេះបន្តិចបន្តួច ។ ខាងក្រោយមកមហាថេរទាំងឡាយជនជាតិស្រីលង្កាបានបង្រៀនដល់ភិក្ខុសង្ឃជនជាតិមន ក្នុងសម័យស្តេចរាមាធិបតីគ្រប់គ្រងក្រុងហង្សវតីរាមញ្ញប្រទេស(ប្រទេសមន) ។ ក្នុងលំដាប់គម្ពីរព្រះត្រៃបិដក អដ្ឋកថា មានក្នុងជំនាន់មុន មិនមានទាល់តែសោះនូវរបៀបបញ្ចូនតាពងនេះ ។ តែមានរបៀបធ្វើនូវការបញ្ចូនតាពងនេះ ក្នុងសិលាចារឹកកល្យាណី ក្រោមការឧបត្ថម្ភពីព្រះរាជាជនជាតិមននោះឯង ។ បន្ទាប់មកទើបមានការកំណត់យកជាផ្លូវការនូវការបញ្ចូនតាពងនេះឯង ក្នុងគម្ពីរវិនយាលង្ការដីកា ដែលរចនាដោយព្រះមុនិន្ទឃោសត្ថេរជនជាតិភូមាក្នុងព.ស.២១៩០ រហូតគម្ពីរនេះមានគោលវិនិច្ឆ័យយ៉ាងល្អហ្មត់ចត់ ឥតទាស់ក្នុងព្រះវិន័យបាននាំតៗគ្នា រហូតមកដល់សព្វថ្ងៃនេះតែម្តង ។

របៀបបញ្ចូនតាពងតាមគម្ពីរវិនយាលង្ការដីកាថា ៖

សមូហននាការោ បន ឯវំ វេទិតព្វោ ៖ ឥមានិ ពន្ធិតព្វាយ សីមាយ និមិត្តានំ អន្តោ ច ពហិ ច យថាវុត្តនយេន សមូហនិតព្វសីមដ្ឋានំ អាកាសតលំ វិយ សមំ សុទ្ធំ វិមលំ កត្វា យថាវុត្តមញ្ចប្បមាណំ មញ្ចប្បមាណំ ឋានំ អដ្ឋបទកលេខំ វិយ រជ្ជុនា វា ទណ្ឌេន វា លេខំ ការាបេត្វា លេខានុសារេន តម្ពមត្តិកចុណ្ណេន វា សេតមត្តិកចុណ្ណេន វា វណ្ណវិសេសំ ការាបេត្វា បន្តិ បន្តិ កោដ្ឋាសំ កោដ្ឋាសំ ការាបេត្វា បុព្វេ វុត្តនយេន អារក្ខំ សោធនញ្ច ការាបេត្វា "ឥមានិ សីមំ សមូហនិស្សាមា"តិ ចត្តារោ វា តទុត្តរិ វា សមាន-សំវាសកភិក្ខូ គហេត្វា បឋមបន្តិយំ បឋមកោដ្ឋាសេ មញ្ចដ្ឋានេ ឋត្វា បឋមំ អវិប្បវាសសីមាសមូហនន-

កម្មវាចំ, តតោ សមានសំវាសកសីមាសមូហននកម្មវាចំ
សាវេត្វា តស្មឹ កោដ្ឋាសេយេវ អញ្ញមញ្ញស្ស ឋិតដ្ឋានំ
បរិវត្តេត្វា បរិវត្តេត្វា តិក្ខត្តុំ វា សត្តក្ខត្តុំ វា សមូហនិត្វា
តតោ និក្ខមិត្វា បឋមបន្តិយំយេវ ទុតិយកោដ្ឋាសេ
ឋត្វា តថេវ កត្វា តតោ បឋមបន្តិយំយេវ អនុលោម–
នយេន យាវ អន្តិមកោដ្ឋាសា ឯកេកស្មឹ កោដ្ឋាសេ តថេវ
កត្វា បឋមបន្តិយា បរិក្ខីណាយ ទុតិយបន្តិយា
អន្តិមកោដ្ឋាសេ ឋត្វា តថេវ កត្វា តតោ បដ្ឋាយ
ទុតិយបន្តិយំយេវ បដិលោមនយេន យាវ អាទិកោដ្ឋាសា
តថេវ កត្វា ឯវំ តតិយបន្តិអាទីសុបិ ឯកទា អនុលោមតោ
ឯកទា បដិលោមតោ គន្ត្វា សព្វាសុ បន្តីសុ សព្វស្មឹ

កោដ្ឋាសេ បរិក្ខីណោ ឥទំ សីមាសមូហននកម្មំ និដ្ឋិតំ នាម ហោតិ ។

ចំណែកកិរិយាដកនូវសីមា បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ៖

ទីមានប្រមាណប៉ុនគ្រែ ដែលប្រមាណប៉ុនគ្រែដូចពោលហើយ គប្បីធ្វើឲ្យស្មើ ស្អាត មិនមានមន្ទិល ឲ្យដូចជាផ្ទៃនៃក្របក់ ក្នុងសីមដ្ឋានដែលគប្បីដកតាមន័យពោលហើយ ទាំងខាងក្នុងនិងខាងក្រៅនៃនិមិត្តក្នុងសីមាដែលគប្បីចង ហើយធ្វើស្នាម ដោយខ្សែឬដំបងឲ្យដូចជាក្រឡាចត្រង្គ និងធ្វើពណ៌ពិសេសដោយលំអិតដីក្រហមឬលំអិតដីស ដែលជាប់តាមស្នាម ហើយធ្វើតារាងឲ្យជាកោដ្ឋាសៈ កោដ្ឋាសៈ (ចំណែកទីមួយៗ) បន្ទាប់មកធ្វើការរក្សានិងជម្រះតាមន័យពោលហើយក្នុងកាលមុន ហើយកាន់យកសមានសំវាសកភិក្ខុ ៤ អង្គ ឬច្រើនជាងបួនអង្គនិងពោលថា “ឥឡូវនេះ យើងនឹងដកនូវសីមា” ដូច្នេះ គប្បីឈរក្នុងផ្ទៃគ្រែ ដែលជាកោដ្ឋាសៈទី ១ ក្នុងតារាងទី ១ ហើយសូធ្យនូវកម្មវាចាដកអវិប្បវាសសីមាជាដំបូងចុះ, បន្ទាប់មកសូធ្យកម្មវាចាដកនូវសមានសំវាសកសីមា គប្បីត្រឡប់ទៅ ៗ ទីឈរក្នុងកោដ្ឋាសៈនោះឯង ទៅវិញទៅមក ហើយសូធ្យដកជាគម្រប់ ៣ ដងឬ ៧ ដង, បន្ទាប់មកចេញពី

នោះ គប្បីឈរនៅក្នុងកោដ្ឋាសៈទី ២ ក្នុងតារាងទី ១ នោះឯង, ហើយធ្វើដូច្នោះទៀត, បន្ទាប់មកធ្វើដូច្នោះទៀត ក្នុងកោដ្ឋាសៈទីមួយ ៗ ដរាបដល់កោដ្ឋាសៈទីបំផុត ដោយអនុលោមន័យក្នុងតារាងទី ១ នោះឯង,កាលអស់តារាងទី ១ ហើយ គប្បីឈរនៅក្នុងកោដ្ឋាសៈទីបំផុតនៃតារាងទី ២ ហើយធ្វើដូច្នោះទៀតចាប់តាំងពីតារាងទី ២ នោះឯង ដោយបដិលោមន័យ ដរាបដល់កោដ្ឋាសៈខាងដើម, គប្បីធ្វើដូចគ្នា សូម្បីតារាងទី ៣ យ៉ាងនេះ ដោយអនុលោមចំណែកមួយ ដោយបដិលោមចំណែកមួយ រហូតគ្រប់តារាងទាំងអស់ តាមលំដាប់, កាលកោដ្ឋាសៈទាំងពួងអស់ហើយ សីមាសម្មុហននកម្មនេះ ឈ្មោះថា សម្រេចហើយ ។

របៀបធ្វើតារាងនីមួយៗត្រូវយកប៉ុនគ្រែ មានក្នុងវិមតិ-វិនោទនីដីកាថា ៖

វិហារបរិក្ខេបស្ស អន្តោ ច ពហិ ច សមន្តា លេឌ្ឌុបាតេ សព្វត្ថ មញ្ចប្បមាណេ ឱកាសេ ឋត្វា ឋត្វា បឋមំ អវិប្បវាសសីមំ ។

គប្បីឲ្យភិក្ខុឈរតាមលំដាប់គ្នាក្នុងឱកាសប្រមាណប៉ុនគ្រែក្នុងទីទាំងពួង ក្នុងទីមួយ លេឌ្ឌុចាត (ទីធ្លាក់ដុំដីដែលមជ្ឈិមបុរសបោះទៅ) ជុំវិញទាំងខាងក្នុងនិងខាងក្រៅនៃទីឡោមព័ទ្ធវត្ត (របងវត្ត) ហើយសូធ្យកម្មវាចាដកអវិប្បវាសសីមាជាដំបូងមុនចុះ ។

នៅក្នុងវិនយាលង្ការដីកាខែប្រមាណគ្រែថា ៖

សព្វបច្ឆិមប្បមាណាយុត្តោ មញ្ចោ ។ សោ ហិ បកតិវិទត្ថិយា នវវិទត្ថិកោ, អដ្ឋវិទត្ថិកោ វា ហោតិ ។

គ្រែដែលប្រកបដោយប្រមាណតូចបំផុត ។ មែនពិតគ្រែនោះឯង មានប្រវែង ៩ ចំអាមឬ ៨ ចំអាម ដោយចំអាមធម្មតា ។

មញ្ចស្ស វិត្ថារោ បន អាយាមស្ស ឧបឌ្ឍោ ហោតិ ។

ចំណែកទទឹងនៃគ្រែ មានប្រវែងពាក់កណ្ដាលនៃបណ្ដោយនោះឯង ។

# របៀបធ្វើតាពង

តាពងត្រូវធ្វើកោដ្ឋាសៈប៉ុនមួយគ្រែដោយពណ៌ពិសេស អាចមើលឃើញច្បាស់បាន ដូច ពណ៌ស ពណ៌ក្រហម មាន ក្រឡាតាពងដូចជាអុក មានការធ្វើទាំងក្នុងនិងខាងក្រៅនៃវត្ត មួយ លេឌ្ឌុចាត (មួយបោះដុំដី) ហើយធ្វើការបញ្ជាន់ទៅតាម អនុលោម បដិលោមតាមន័យដែលមានមកហើយក្នុងវិនយា-លង្ការដីកានោះឯង ។



# ផ្ទៃតារាងមួយគ្រឿ



# ញត្តិសម្មតសមានសំវាសកសីមា

សុណាតុ មេ ភន្តេ សង្ឃោ ។ យាវតា សមន្តា និមិត្តា កិត្តិតា ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នេយ្យ សមានសំវាសំ ឯកុបោសថំ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ។ យាវតា សមន្តា និមិត្តា កិត្តិតា ។ សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នតិ សមានសំវាសំ ឯកុបោសថំ ។ យស្សាយស្មតោ ខមតិ ឯតេហិ និមិត្តេហិ សីមាយ សម្មតិ សមានសំវាសាយ ឯកុបោសថាយ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សម្មតា សីមា សង្ឃេន ឯតេហិ និមិត្តេហិ សមានសំវាសា ឯកុបោសថា ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ និមិត្រទាំងឡាយ ដែលសង្ឃកំណត់ហើយដោយជុំវិញ មានកំណត់ត្រឹមណា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតសីមាឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នាដោយនិមិត្រទាំងឡាយនេះ កំណត់ត្រឹមនោះ ។ នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ និមិត្រទាំងឡាយដែលសង្ឃកំណត់ហើយដោយជុំវិញ មានកំណត់ត្រឹមណា ឥឡូវសង្ឃសន្មតសីមាឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្រទាំងឡាយនេះ មានកំណត់ត្រឹមនោះ ។ សេចក្តីសន្មតិសីមាឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្រទាំងឡាយនេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នាសង្ឃបានសន្មតដោយនិមិត្រទាំងឡាយនេះហើយ ។ ការសន្មតិសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

## ញត្តិសន្មតតិចីវរាវិប្បវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នេយ្យ, ឋបេត្វា គាមញ្ច គាមូបចារញ្ច ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នតិ, ឋបេត្វា គាមញ្ច គាមូបចារញ្ច ។ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ តិចីវរេន អវិប្បវាសាយ សម្មុតិ, ឋបេត្វា គាមញ្ច គាមូបចារញ្ច, សោ តុណ្ហស្ស; យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សម្មតា សា សីមា សង្ឃេន តិចីវរេន

អវិប្បវាសា, ឋបេត្វា គាមញ្ច គាមូបចារញ្ច ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សីមាណា ដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតសីមានោះ ឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុកនិងឧបចារៈរបស់ស្រុកចេញ ។ នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សីមាណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ឥឡូវសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុកនិងឧបចារៈរបស់ស្រុកចេញ ។ ការសន្មតិសីមានេះឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុកនិងឧបចារៈរបស់ស្រុកចេញ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ សង្ឃបានសន្មតសីមានេះឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុកនិងឧបចារៈស្រុកចេញហើយ ។ ការ

សន្មតិនោះគាប់ចិត្តដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

## ដកតិចីវរាវិប្បវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ ។ យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនេយ្យ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ។ យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ, សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនតិ ។ យស្សាយស្មតោ ខមតិ ឯតស្ស តិចីវរេន អវិប្បវាសស្ស សមុគ្ឃាតោ, សោ តុណ្ហស្ស; យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតោ សោ

សង្ឃេន តិចីវរេន អវិប្បវាសោ ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ តិចីវរា-វិប្បវាសសីមាណា ដែលសង្ឃសន្មតហើយ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវដកតិចីវរាវិប្បវាសសីមានោះចេញ ។ នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ តិចីវរា-វិប្បវាសសីមាណា ដែលសង្ឃសន្មតហើយ ឥឡូវសង្ឃដកតិចីវរាវិប្បវាសសីមានោះចេញ ។ ការដកនូវតិចីវរាវិប្បវាស-សីមានេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ តិចីវ-រាវិប្បវាសសីមានោះសង្ឃបានដកហើយ ។ ការដកនូវតិចីវរា-វិប្បវាសសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម ។ ឯខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ ។

# ដកសមានសំវាសកសីមា

សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ សមូហនេយ្យ សមានសំវាសំ ឯកុបោសថំ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, សង្ឃោ តំ សីមំ សមូហនតិ សមានសំវាសំ ឯកុបោសថំ ។ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ សមានសំវាសាយ ឯកុបោសថាយ សមុគ្ឃាតោ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតា សា សីមា សង្ឃេន សមានសំវាសា ឯកុបោសថា ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សីមាណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នាហើយ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃដកសីមាដែលមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះចេញ ។ នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សីមាណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នាហើយ ឥឡូវសង្ឃដកសីមាដែលមានសំវាសស្មើគ្នាមានឧបោសថជាមួយគ្នានោះចេញ ។ ការដកសីមាដែលមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ សង្ឃដកសីមាដែលមានសំវាស ស្មើគ្នា មានឧបោសថជាមួយគ្នានោះហើយ ។ ការដកសមានសំ-វាសសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

## សេចក្ដីបញ្ជាក់ចាឋៈនៃការសម្មតិនិងការជក

នៅក្នុងព្រះត្រៃបិដក មហាវគ្គ ភាគ ៦ ទំព័រ ៣៥៩ បន្ទាត់ទី ៨ មានបាឋៈថា យស្សាយស្មតោ ខមតិ ឋតិស្សា សីមាយ តិចីវរេន **អវិប្បវាសស្ស** សម្មុតិ, ឋបេត្វា គាមញ្ច គាមូបចារញ្ច, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។

ត្រង់បាឋៈថា អវិប្បវាសស្ស នេះជាពាក្យភ្លាត់គួរមានរូបដូច្នេះ យស្សាយស្មតោ ។ល។ តិចីវរេន **អវិប្បវាសាយ** ។ល។ សោ ភាសេយ្យ ។

កាលខ្ញុំសិក្សានូវបាឋៈ ក្នុងព្រះត្រៃបិដកនេះទៅក៏គិតឃើញថា ពាក្យនេះគួរភ្លាត់ខុសមិនខាន ពេលបានសិក្សាក្នុងព្រះត្រៃបិដក ឆដ្ឋសង្គាយនា និងមើលក្នុងសង្ឃកម្មកថា ភាគ ១ ទំព័រ ៤២ បន្ទាត់ទី ៥ របស់ព្រះឧបាលិវង្ស ម៊ឹង សែស ក៏ឃើញរូបសព្ទថា អវិប្បវាសាយ ដូចគ្នានឹងឆដ្ឋសង្គាយនា ។

ត្រង់បាឋៈថា សម្មតា សា សីមា សង្ឃេន តិចីវរេន **អវិប្បវាសោ** នៅក្នុងព្រះត្រៃបិដក មហាវគ្គ ភាគ ៦ ទំព័រ ៣៥៩ បន្ទាត់ទី ១១ នេះ ត្រូវមានរូបដូច្នេះ សម្មតា សា សីមា សង្ឃេន តិចីវរេន **អវិប្បវាសា** វិញ ។ កាលមានរូបជា អវិប្បវាសា ឲ្យត្រូវគ្នានឹង សីមា ដែលជាឥត្ថីលិង្គ ។ នៅក្នុងវិនយបិដក មហាវគ្គ ឆដ្ឋសង្គាយនាមានរូបជា អវិប្បវាសា ទាំងក្នុងសង្ឃកម្មកថា ភាគ ១ ទំព័រ ៤២ បន្ទាត់ទី ៧ របស់ព្រះឧបាលិវង្ស ម៉ឹង សែស ក៏ឃើញរូបសព្ទថា អវិប្បវាសា ដូចគ្នានឹងឆដ្ឋសង្គាយនា ។

ចំពោះបាឋៈនៃការដកសមានសំវាសសីមា ក្នុងវិនយបិដក មហាវគ្គ ភាគ ៦ ទំព័រ ៣៦១ ចាប់ពីបន្ទាត់ទី ២ ទៅមានយ៉ាងនេះ សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, យទិ សង្ឃស្ស បត្តកល្លំ, **សង្ឃោ តំ សីមំ សមូហនេយ្យ** ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ។ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, **សង្ឃោ តំ សីមំ សមូហនតិ** ។ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ សមានសំវាសាយ ឯកុបោសថាយ សមុគ្ឃាតោ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតា សា សីមា សង្ឃេន សមានសំវាសា ឯកុបោសថា ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

*តែក្នុងសៀវភៅនេះ មានបាឋៈបន្ថែមខ្លះទៀតនៅត្រង់* សង្ឃោ តំ សីមំ សមូហនេយ្យ *មានបាឋៈបន្តថា* សមាន-សំវាសំ ឯកុបោសថំ *មានរូបសព្ទដូច្នេះ* សង្ឃោ តំ សីមំ សមូហនេយ្យ សមានសំវាសំ ឯកុបោសថំ ។

ការបន្ថែមមកទៀតនេះ ដើម្បីឲ្យត្រូវក្នុងអដ្ឋកថា ដីកាទាំងឡាយដែលលោកបានពោលមកហើយ និងមានប្រាកដក្នុងវិនយបិដក មហាវគ្គ ឆដ្ឋសង្គាយនាផងដែរ ។ ការសង្កេតពិនិត្យឲ្យច្បាស់លាស់ថែមទៀតក្នុងវិនយបិដក មហាវគ្គ ភាគ ៦ ទំព័រ ៣៦១ ចាប់ពីបន្ទាត់ទី ១៤ ទៅ នឹងមានឃើញពាក្យនយលក្ខណៈ (លេខយោង) ដែលសង្គីតិកាចារ្យក្រុមជំនុំព្រះត្រៃបិដក មានការចង្អុលបង្ហាញពីបាបៈនៃការដកសីមាយ៉ាងណាហើយ ។ តែគួរសង្កេតពិនិត្យត្រង់ពាក្យក្រុមជំនុំប្រាប់ថា អម្ហាកម្បនាយំ ខន្តិ សុណាតុ មេ ភន្តេ ។ល។ ឯវមេតំ ធារយាមីតិ ។

បាបៈនៃការដកសមានសំវាសកសីមា ក្នុងវិនយបិដក មហាវគ្គនេះ ជាយោបល់របស់ក្រុមជំនុំ (អម្ហាកម្បនាយំ ខន្តិ) ក្នុងកាលណោះទេ គឺមិនទាន់ច្បាស់លាស់នៅឡើយ ។ ពេលចាប់សិក្សាក្នុងអដ្ឋកថា ដូចជាគម្ពីរវិនយសង្គហដ្ឋកថា វិនយាលង្ការដីកា ទើបកាត់សង្ស័យបានថា ត្រូវមានបាបៈ សមានសំវាសំ ឯកុបោសថំ ថែមទៀត ។

# ហត្ថបាសនៃសង្ឃកម្ម

ពាក្យថាហត្ថបាស បានន័យថា អន្ទាក់នៃដៃ, ទីជិតនៃដៃ, ទីឱកាសនៃដៃ, ដូចមានក្នុងគម្ពីរបាចិត្យាទិយោជនាខែថា ហត្ថបាសោតិ ហត្ថស្ស បាសោ សមីបោ ហត្ថបាសោ ។ ហត្ថោ បសតិ ផុសតិ អស្មឹ ឋានេតិ វា ហត្ថបាសោ ។

នៅក្នុងអដ្ឋកថាមានសំដែងពាក្យថា ហត្ថបាសៗក្នុងរឿងការធ្វើសង្ឃកម្មនេះច្រើនណាស់ ។ តែមិនមានឃើញបញ្ជាក់ទាល់សោះនូវហត្ថបាសនៃសង្ឃកម្មនេះ ។ ក្នុងអដ្ឋកថាមានបញ្ជាក់តែហត្ថបាសនៃការប្រគេន ក្នុងបឋមបារាជិកសិក្ខាបទទី ២ ក្នុងបាចិត្តិយកណ្ឌថា ឧាយកោ អឌ្ឍតេយ្យហត្ថប្បមាណោ ឱកាសេ ហោតិ ។ ទាយកស្ថិតនៅក្នុងឱកាសប្រមាណ ២ ហត្ថ ១ ចំអាម ឈ្មោះថា ហត្ថបាស ។

កាលមិនឃើញមានពាក្យ ហត្ថបាស នៃសង្ឃកម្មក្នុង អដ្ឋកថាទាំងឡាយ ក៏នាំគ្នាកាន់យកហត្ថបាសនៃការប្រគេននេះ ថា ជាហត្ថបាសនៃសង្ឃកម្ម ។ តែខាងក្រោយមកមានការ ពន្យល់ពាក្យថា ហត្ថបាស នេះក្នុងដីកាចារ្យគឺគម្ពីរវិនយត្ថ-មញ្ជូសាថា ហត្ថបាសោ នាម ទិយឌ្ឍហត្ថប្ប-មាណោ។ ប្រមាណ ១ ហត្ថ ១ ចំអាម ឈ្មោះថា ហត្ថបាស នៃសង្ឃកម្ម ។

ហត្ថបាសនៃសង្ឃកម្មនេះ វាស់ផ្សេងពីហត្ថបាសនៃការ ប្រគេនគឺមិនដូចគ្នា ក្នុងបឋមបវារណាសិក្ខាបទវាប់ ២ ហត្ថ ១ ចំអាម យកភិក្ខុជាប្រធាន ។ ចំណែកហត្ថបាសនៃសង្ឃកម្មគឺ វាស់ ១ ហត្ថ ១ ចំអាមពីភិក្ខុមួយទៅភិក្ខុមួយរូបទៀតតែម្ដង មិនមានកាត់ចោលថា នៅសល់ត្រឹមមួយចំអាមនោះទេ ដូចនៅ ក្នុងគម្ពីរអនុវណ្ណនាដីកាបាតិមោក្ខបញ្ជាក់ថា ៖

ឯតេន ទិយឌ្ឍហត្ថប្បមាណោ បទេសោ គហេតព្វោ, ន ទ្វាទសហត្ថបាសោ, អញ្ញមញ្ញវសេន, បដិគ្គហណសិក្ខាបទេ អាគតោ អឌ្ឍតេយ្យហត្ថបាសោ ភិក្ខុបធានវសេន វេទិតព្វោ ។

*ហត្ថបាសសង្ឃកម្មនេះ បណ្ឌិតគប្បីកាន់យកទីចម្ងាយ ១ ហត្ថ ១ ចំអាម, មិនមែនហត្ថបាស ១២ ហត្ថទេ, ហត្ថបាសសង្ឃកម្មចម្ងាយ ១ ហត្ថ ១ ចំអាម ដែលមានមកក្នុងសង្ឃកម្មនេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃគ្នានឹងគ្នា, ហត្ថបាសប្រគេន ២ ហត្ថ ១ ចំអាម ដែលមានមកក្នុងបដិគ្គហណសិក្ខាបទ (ទន្តបោណសិក្ខាបទ) គប្បីជ្រាបដោយអំណាចនៃភិក្ខុជាប្រធាន ។*

# សីមាសង្ករៈ

*នៅក្នុងអដ្ឋកថាពោលពីសីមាសង្ករៈដូច្នេះ ៖*

សីមាមាឡកេ វដ្ដរុក្ខោ ហោតិ, តស្ស សាខា វា តតោ និគ្គតបារោហោ វា មហាសីមាយ បថវិតលំ វា តត្ថជាតរុក្ខាទីនិ វា អាហច្ច តិដ្ឋតិ, មហាសីមំ សោធេត្វា វា កម្មំ កាតព្វំ, តេ វា សាខាបារោហា ឆិន្ទិត្វា ពហិដ្ឋកា កាតព្វា ។ អនាហច្ចឋិតសាខាទីសុ អារុឡ្ហភិក្ខុ ហត្ថបាសំ អានេតព្វោ ។

*មានដើមជ្រៃមួយដើមក្នុងផ្ទៃខណ្ឌសីមា, មែករបស់ដើមជ្រៃនោះក្តី ពួរដែលដុះចេញពីដើមជ្រៃនោះក្តី ធ្លាក់ចុះទៅប៉ះផ្ទៃដីក្នុងមហាសីមាឬជាប់នឹងវត្ថុទាំងឡាយមានដើមឈើជាដើមដែលកើតក្នុងផ្ទៃមហាសីមានោះ, គប្បីជម្រះគឺនាំភិក្ខុដែលនៅក្នុងមហាសីមាមកកាន់ហត្ថបាសហើយធ្វើកម្មចុះក៏បាន, ឬក៏កាត់មែកនិងពួរជ្រៃនោះចេញទៅខាងក្រៅ ហើយធ្វើសង្ឃកម្មចុះ ។*

*បើមានភិក្ខុឡើងដើមឈើ ទោះបីលោកនៅលើចុងឈើមិនជាប់ដីក៏ពិតមែន ត្រូវនាំលោកមកកាន់ហត្ថបាស ។*

ឯវំ មហាសីមាយ ជាតរុក្ខស្ស សាខា វា

ចារោហោ វា វុត្តនយេនេវ សីមាមាឡកេ បតិដ្ឋាតិ,

វុត្តនយេនេវ សីមំ សោធេត្វា វា កម្មំ កាតព្វំ, តេ វា

សាខាចារោហា ឆិន្ទិត្វា ពហិដ្ឋកា កាតព្វា ។

*មែកឬពួររបស់ឈើ ដែលកើតក្នុងមហាសីមាយ៉ាងនេះ ហើយទៅប៉ះក្នុងផ្ទៃខណ្ឌសីមា តាមន័យពោលហើយនោះឯង, គប្បីជម្រះនូវសីមា តាមន័យពោលហើយនោះឯង ហើយធ្វើសង្ឃកម្មចុះ,ឬក៏កាត់មែកនិងពួរនោះចេញទៅខាងក្រៅ ហើយធ្វើសង្ឃកម្មចុះ ។*

ពទ្ធសីមាយ ជាតំ យំកិញ្ចិ យត្ថ កត្ថចិ

ឯកសម្ពន្ធេន គតំ សីមាសង្ខ្យមេវ គច្ឆតិ ។

*វត្ថុយ៉ាងណាមួយក៏ដោយ ដែលកើតក្នុងពទ្ធសីមា ដល់នូវការជាប់ទាក់ទងគ្នាក្នុងទីណាមួយ ទីនោះរមែងដល់ការរាប់ថាជាសីមាពិតប្រាកដ ។*

*វិមតិវិនោទនីដីកាថែថា ៖*

ឯកសម្ពន្ធេន គតន្តិ រុក្ខលតាទិតត្រជាតមេវ សន្ធាយ វុត្តំ ។

*ត្រង់ពាក្យថា ដល់នូវការជាប់ទាក់ទងគ្នា មានសេចក្ដីថា អដ្ឋកថាចារ្យពោលសំដៅនូវវត្ថុយ៉ាងណាមួយ ដែលកើតក្នុងពទ្ធសីមានោះមានដើមឈើនិងវល្លិជាដើម ។*

*បាចិត្យាទិយោជនាថែថា ៖*

យំកិញ្ចីតិ យំកិញ្ចិ បព្វតាទិ ។ យត្ថ កត្ថចីតិ យស្មិំ កស្មិំចិ ឋានេ ។ ឯកសម្ពន្ធេនាតិ ពទ្ធសីមាយ ឯក-សម្ពន្ធេន ។

*ត្រង់ពាក្យថា យ៉ាងណាមួយ គឺវត្ថុទាំងឡាយមានភ្នំជាដើមយ៉ាងណាមួយ ។ ត្រង់ពាក្យថា ក្នុងទីណាមួយ គឺក្នុងទីណា*

កន្លែងណា ។ ត្រង់ពាក្យថា ដោយការជាប់ទាក់ទងគ្នា គឺជាប់ទាក់ទងគ្នាក្នុងពទ្ធសីមា ។

វិនយាលង្ការដីកាថែថា ៖

ជាតំ យំ កិញ្ចិ និដ្ឋិតសីមាយ ឧបរិ ជាតំ

វិជ្ជមានំ បុព្វេ ឋិតំ បច្ឆា សញ្ជាតំ បរិដ្ឋញ្ច យំ កិញ្ចិ

សវិញ្ញាណកាវិញ្ញាណកំ សព្វម្បិ តិ អត្ថោ ។

វត្ថុដែលកើតលើសីមា ដែលសម្រេចហើយតាំងនៅក្ដី កើតខាងក្រោយសីមាក្ដី ចូលទៅក្នុងផ្ទៃសីមាក្ដី អធិប្បាយថា វត្ថុយ៉ាងណាមួយសូម្បីទាំងអស់ ទោះមានវិញ្ញាណក៏ដោយ មិនមានវិញ្ញាណក៏ដោយ ។

សីមាសង្ករ: មានន័យថា សីមាដែលកើតដោយសារ

ចូងចេញពីសីមាមួយទៀត ។ ដូចផ្ទៃមហាសីមានៅជិតខណ្ឌ-សីមា មានវត្ថុណាមួយចូងទៅប៉ះនឹងសីមាមួយទៀត ធ្វើឲ្យទៅជាសីមាជាមួយគ្នា ត្រូវមានសង្ឃកម្មជាមួយគ្នា ។ បើធ្វើសង្ឃ-កម្ម ដោយមិននិមន្តភិក្ខុនៅក្នុងផ្ទៃសីមាមួយទៀតមកទេ សង្ឃ-

កម្មរបស់សង្ឃនោះ ត្រូវខូច ដោយបរិសវិបត្តិ ។ នៅក្នុង អដ្ឋកថាបញ្ជាក់ពីពទ្ធសីមាពីរនៅជិតគ្នាគឺ អវិប្បវាសសីមា និង ខណ្ឌសីមា ។ បើមានដើមឈើឬវត្ថុណាមួយតោងទៅប៉ះសីមា មួយទៀត កាលធ្វើសង្ឃកម្មត្រូវនិមន្តភិក្ខុទាំងអស់មកជួបជុំគ្នា។ បើមិនដូច្នោះ ត្រូវកាត់វត្ថុទាំងនោះចេញ កុំឲ្យប៉ះគ្នាទៀត ទើប គួរដល់សង្ឃកម្ម ។ វត្ថុណាមួយដែលជាប់នៅក្នុងសីមាណា មួយ ហើយចេញទៅក្រៅផ្សេង ឬចេញទៅជាប់សីមាមួយទៀត នោះ ក៏សង្ករៈដូចគ្នា ។ ដូចដើមដូងមួយដើមនៅក្នុងខណ្ឌសីមា ដុល ហើយមានដើម ឬគល់ជាប់នៅក្នុងខណ្ឌសីមាខ្វះ មាន ចំណែកខ្វះចេញទៅខាងក្រៅផុតពីខណ្ឌសីមា មានភិក្ខុមួយអង្គ នៅខាងក្រៅខណ្ឌសីមាទេ គង់លើឬប៉ះដើមដូងនោះ ។ ប្រសិន បើសង្ឃកំពុងធ្វើសង្ឃកម្ម កម្មនោះរមែងខូច ដោយហេតុតែ **សីមាសង្ករៈ** ។ សីមាសង្ករៈនេះ សូម្បីត្រឹមប៉ះស្បង់ ចីវររបស់ លោកកំពុងគ្រង ក៏សីមាសង្ករៈដែរ ។

សីមាសង្ករៈ ជាមួយ វិសភាគសីមា ។ មិនសង្ករៈជា

មួយ សភាគសីមាទេ ។

## ពទ្ធសីមា

ពទ្ធសីមា សង្ករៈជាមួយ ពទ្ធសីមា[១] ។

ពទ្ធសីមា សង្ករៈជាមួយ ឧទកុក្ខេបសីមា ។

ពទ្ធសីមា សង្ករៈជាមួយ សត្តព្ភន្តរសីមា ។

## ឧទកុក្ខេបសីមា

ឧទកុក្ខេបសីមា សង្ករៈជាមួយ គាមសីមា ។

ឧទកុក្ខេបសីមា សង្ករៈជាមួយ សត្តព្ភន្តរសីមា ។

ឧទកុក្ខេបសីមា សង្ករៈជាមួយ ឧទកុក្ខេបសីមា ។

ឧទកុក្ខេបសីមា សង្ករៈជាមួយ ពទ្ធសីមា ។

## សត្តព្ភន្តរសីមា

សត្តព្ភន្តរសីមា សង្ករៈជាមួយ ពទ្ធសីមា ។

សត្តព្ភន្តរសីមា សង្ករៈជាមួយ គាមសីមា ។

សត្តព្ភន្តរសីមា សង្ករៈជាមួយ ឧទកុក្ខេបសីមា ។

---

១ ពទ្ធសីមាមាន ៣ គឺ សមានសំវាសកសីមា អវិប្បវាសសីមា ខណ្ឌសីមា ។ សីមាទាំងបីនេះ សង្ករៈគ្នាទៅវិញទៅមក ។

# សត្តព្ភន្តរសីមា សង្ករៈជាមួយ សត្តព្ភន្តរសីមា ។

## គាមសីមា

គាមសីមា សង្ករៈជាមួយ សត្តព្ភន្តរសីមា ។

គាមសីមា សង្ករៈជាមួយ ឧទកុក្ខេបសីមា ។

ចំពោះ គាមសីមា មិនសង្ករៈជាមួយពទ្ធសីមាឡើយ ។ ព្រោះសីមាទាំងពីរនេះ ជា សភាគសីមានឹងគ្នា ។ ចំណែកសីមាផ្សេងទៀត ជាវិសភាគសីមានឹងគ្នា ។ ដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា ន ភិក្ខវេ សីមាយ សីមា សម្ភិន្ទិតព្វា[1] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំលាយសីមាដោយសីមាទេ ។

អនុជានាមិ ភិក្ខវេ សីមំ សម្មន្នន្តេន សីមន្តរិកំ ឋបេត្វា សីមំ សម្មន្និតុំ[2] ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុសន្មតសីមា ឲ្យតម្កល់ទុកនូវសីមន្តរិកហើយសឹមសន្មតសីមា ។

---

១-២ វិនយបិដក មហាវគ្គ ៦ ទំព័រ ៣៦៣-៣៦៤ ។

កាលព្រះមានព្រះភាគទ្រង់បញ្ញត្ត មិនឲ្យទំលាយសីមា និងមិនឲ្យគ្របសង្កត់សីមាដោយសីមា និងព្រះអង្គទ្រង់អនុញ្ញាតឲ្យតម្កល់សីមន្តរិកនេះហើយ ទើបអដ្ឋកថាចារ្យកាន់យកពង្រីកសេចក្ដីឲ្យដឹងពីសីមាសង្ករៈនឹងគ្នា ។ តែពទ្ធសីមាមិនសង្ករៈជាមួយនឹងគាមសីមានោះ ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យចងពទ្ធសីមាក្នុងគាមសីមា ។ ហេតុនេះសីមាទាំងពីរនេះត្រូវអាស្រ័យគ្នា ទើបសីមានេះ សភាគសីមានឹងគ្នា ។

សីមាសង្ករៈនេះដីកាចារ្យបញ្ជាក់ហើយ អាចសង្ករៈបានទាំងអស់ ទោះបីវត្ថុនោះមានវិញ្ញាណក៏ដោយ មិនមានវិញ្ញាណក៏ដោយ ដូចវិនយាលង្ការដីកាខែថា សព្វរុក្ខលតាទីនម្បិ សម្ពន្ធោ ន វដ្ដតិ ឯវំ ។ តេនេវ ឆាវារដ្ឋិសេតុសម្ពន្ធោបិ បដិក្ខិត្តោ ។ ការជាប់ទាក់ទងដោយវត្ថុទាំងឡាយ មានដើមឈើនិងវល្លិទាំងពួង មិនគួរទាល់តែសោះ ។ ព្រោះហេតុនោះឯង សូម្បីទូក ខ្សែ ស្ពាន ក៏អដ្ឋកថាចារ្យហាមឃាត់ហើយ ។

ដីកាចារ្យលោកអានពាក្យអដ្ឋកថាចារ្យពោលទុកនៅក្នុង ឧទកុក្ខេសីមាថា ៖

អន្តោនទិយំ ជាតរុក្ខេ វា ពន្ធិត្វា កម្មំ កាតព្វំ ។ អន្តោនទិយំ ពទ្ធអដ្ដកេបិ អន្តោនទិយំ ជាតរុក្ខេបិ ឋិតេហិ កាតុំ វដ្ដតិ ។

បើភិក្ខុធ្វើសង្ឃកម្មក្នុងស្ទឹង គប្បីចងទូកនឹងដើមឈើ ដែលកើតនៅក្នុងស្ទឹងនោះឯង ហើយធ្វើចុះ (មិនត្រូវចងទៅដើមឈើដែលដុះទៀបច្រាំងស្ទឹងឡើយ កាលចងសីមាសន្តរៈនឹងគ្នា) ។

សចេ បន រុក្ខស្ស សាខា វា តតោ និក្ខន្ត-បារោហោ វា ពហិនទីតីរេ វិហារសីមាយ វា គាមសីមាយ វា បតិដ្ឋិតោ, សីមំ វា សោធេត្វា សាខំ វា ឆិន្ទិត្វា កម្មំ កាតព្វំ ។

ប្រសិនបើមែករបស់ដើមឈើក្តី ពួរដែលដុះចេញពីដើមឈើនោះក្តី ធ្លាក់ទៅប៉ះក្នុងប្រាំងស្ទឹងខាងក្រៅ ឬប៉ះក្នុងវិហារសីមា គឺពទ្ធសីមា ឬក៏គាមសីមា, គប្បីជម្រះគឺនាំភិក្ខុនៅក្នុងពទ្ធសីមា ឬ ក្នុងគាមសីមាមកកាន់ហត្ថបាស ហើយធ្វើសង្ឃកម្មចុះ ។

ពហិនទីតីរេ ជាតរុក្ខស្ស អន្តោនទិយំ បវិដ្ឋ-សាខាយ វា ថារោហេ វា នាវំ ពន្ធិត្វា កម្មំ កាតុំ ន វដ្ដតិ, ករោន្តេហិ សីមា វា សោធេតព្វា, ឆិន្ទិត្វា វាស្ស ពហិបតិដ្ឋិតភាវោ នាសេតព្វោ ។ នទីតីរេ បន ខាណុកំ កោដ្ដេត្វា តត្ថ ពទ្ធនាវាយ ន វដ្ដតិយេវ ។

ភិក្ខុមិនគួរធ្វើសង្ឃកម្មដោយចងទូកនឹងមែកឈើ ដែលកើតក្នុងប្រាំងស្ទឹងខាងក្រៅលយចូលទៅខាងក្នុងស្ទឹងនោះឡើយ, កាលភិក្ខុធ្វើសង្ឃកម្ម ត្រូវជម្រះសីមា ឬកាត់មែកនោះឲ្យអស់វិនាសចេញទៅខាងក្រៅ ។ កាលភិក្ខុធ្វើសង្ឃកម្មដោយចងទូកទៅនឹងជង្កត់ឈើដែលបោះភ្ជាប់នឹងប្រាំងស្ទឹង មិនគួរទាល់តែសោះ (គឺសង្ឃកម្មខូចដោយសីមាសង្ករៈ) ។

នទិយំ សេតុំ ករោន្តិ, សចេ អន្តោនទិយំយេវ សេតុ ច សេតុបាទា ច ហោន្តិ, សេតុម្ហិ ឋិតេហិ កម្មំ កាតុំ វដ្តតិ។ សចេ បន សេតុ វា សេតុបាទា វា ពហិតីរេ បតិដ្ឋិតា, កម្មំ កាតុំ ន វដ្តតិ, សីមំ សោធេត្វា កាតព្វំ។ អថ សេតុបាទា អន្តោ, សេតុ បន ឧភិន្នម្បិ តីរានំ ឧបរិ អាកាសេ ឋិតោ, វដ្តតិ។

*មនុស្សទាំងឡាយធ្វើស្ពានក្នុងស្ទឹង, ប្រសិនបើស្ពានក្តី ជើងស្ពានក្តី មានតែក្នុងស្ទឹងប៉ុណ្ណោះឯង, ភិក្ខុទាំងឡាយស្ថិតនៅក្នុងស្ពាននោះ គួរធ្វើសង្ឃកម្មបាន ។ ប្រសិនបើស្ពានក្តី ជើងស្ពានក្តី ជាប់នឹងច្រាំងខាងក្រៅ មិនគួរធ្វើសង្ឃកម្មទាល់តែសោះ, គប្បីជម្រះសីមាជាមុន ហើយទើបគួរធ្វើ ។ បើជើងស្ពានមានតែខាងក្នុងស្ទឹងប៉ុណ្ណោះ, ចំណែកឯតួស្ពាន ស្ថិតនៅលើអាកាសនៃច្រាំងស្ទឹងទាំងពីរ (មិនជាប់នឹងច្រាំងទាំងពីរខាង) គួរធ្វើសង្ឃកម្មបាន ។*

នៅក្នុងសីមាសង្ករៈទាំងអស់នេះ ដែលមានក្នុងអដ្ឋកថា បានបញ្ជាក់យ៉ាងច្បាស់ថា ទូកក៏ដោយ ខ្សែក៏ដោយ ស្ពានក៏ដោយ មែកឈើ ឬពួរឈើ វល្លិឈើក៏ដោយ សុទ្ធតែសង្ករៈទាំងអស់ ។

នៅក្នុងសម័យបច្ចុប្បន្នមានវត្តជិតៗគ្នា ដែលបានចងសីមារួចហើយ ។ ប្រសិនបើមានខ្សែណាមួយចេញពីពទ្ធសីមាមួយ ចូលទៅកាន់ពទ្ធសីមាមួយទៀត សីមាទាំងពីរនេះនឹងសង្ករៈគ្នាមិនខាន ពេលសង្ឃកំពុងធ្វើសង្ឃកម្ម ។

ចប់សីមាសង្ករៈ

# សីមាពន្ធនវិនិច្ឆ័យចប់

## ដោយសង្ខេប

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

## Taking Refuge with a mind of Bodhichitta

In the Buddha, the Dharma and the Sangha,
I shall always take refuge
Until the attainment of full awakening.

Through the merit of practicing generosity
and other perfections,
May I swiftly accomplish Buddhahood,
And benefit of all sentient beings.

## The Prayers of the Bodhisattvas

With a wish to awaken all beings,
I shall always go for refuge
To the Buddha, Dharma, and Sangha,
Until I attain full enlightenment.

Possessing compassion and wisdom,
Today, in the Buddha's presence,
I sincerely generate
the supreme mind of Bodhichitta
For the benefit of all sentient beings.

"As long as space endures,
As long as sentient beings dwell,
Until then, may I too remain
To dispel the miseries of all sentient beings."

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~